Minnesota Department of Education

# ផ្នែក ខ ដំណឹងអំពីទម្រង់ការការពារ

# សិទ្ធិមាតាបិតាសម្រាប់សិស្សទទួលការអប់រំពិសេសនៅសាលារៀនរបស់រដ្ឋ

ខ្លឹមសារនៃឯកសារនេះ គឺដើម្បីផ្តល់ជូននូវព័ត៌មានទូទៅ និងមគ្គុទ្ទេសក៍ អំពីសិទ្ធិចំពោះការអប់រំពិសេស និងទម្រង់ការការពារ ដែលរៀបរៀងឡើងដើម្បីផ្តល់ជូនមាតាបិតា ដែលមានបុត្រអាយុចាប់ពី 3 ដល់ 21ឆ្នាំ ក្រោមច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ ។ នៅក្នុងឯកសារនេះមានពន្យល់អំពីដំណកស្រង់នៃសិទ្ធិ ព្រមទាំងទម្រង់ការការពារ មួយចំនួន ដើម្បីផ្តល់ជូនមាតាបិតា  ស្ថិតនៅក្រោមច្បាប់អប់រំបុគ្គលមានពិការភាព (IDEA)ដែលជាបទបញ្ញត្តិនានាសម្រាប់អនុវត្ត ស្ថិតក្នុង C.F.R 34 ផ្នែកទី 300 ព្រមទាំងច្បាប់ និងបញ្ញត្តិផ្សេងៗដែលអាចអនុវត្តបានរបស់រដ្ឋមីណេសូតា ។ ទោះជាយ៉ាងណាក៏ដោយ វាមិនមែនជាបញ្ជី ឬជាការពន្យល់ពេញបរិបូណ៌ចំពោះសិទ្ធិទាំងអស់នោះឡើយ ។ សេចក្តីជូនដំណឹងនេះ មិនមែនជា អ្វីមួយដែលអ្នកអាចប្រើជំនួសឱ្យការពិគ្រោះយោបល់ជាមួយនឹងស្មាក្តីដែលមានអាជ្ញាប័ណ្ណស្របច្បាប់ អំពីស្ថានភាពផ្លូវច្បាប់ជាក់លាក់របស់អ្នកឡើយ ។ ឯកសារនេះមិន មែនជាអំណះអំណាង ក្នុងការបញ្ចូលនូវការពន្យល់ចំពោះច្បាប់រដ្ឋ និងច្បាប់សហព័ន្ធដែលអនុវត្តបានឡើយ ហើយច្បាប់នោះ អាចប្រែប្រួលតាំងពីពេលដែល ឯកសារនេះ ត្រូវបានសរសេរឡើង ។

## សេចក្តីផ្តើម

ឯកសារនេះ ផ្តល់ជូននូវសេចក្តីសង្ខេបមួយ អំពីសិទ្ធិរបស់មាតាបិតា ចំពោះការ អប់រំពិសេស ដែលជួនកាលគេហៅថាទម្រង់ការការពារ ។ ទម្រង់ការការ ពារដូចគ្នានេះ ក៏មានសម្រាប់សិស្សពិការ ដែលមានអាយុគំរប់ 18ឆ្នាំ ដែរ ។

សេចក្តីជូនដំណឹងអំពីទម្រង់ការការពារនេះ ត្រូវតែផ្តល់ឱ្យអ្នក យ៉ាងហោចណាស់ ក៏មួយដងដែរ ក្នុងមួយឆ្នាំ ។ គេក៏ត្រូវតែផ្តល់ឱ្យអ្នកផងដែរនូវ :

1. ការបញ្ជូនកូនរបស់អ្នក ជាលើកទីមួយ ឱ្យទៅទទួល ការវាយតម្លៃសម្រាប់ ការអប់រំពិសេស ឬប្រសិនបើអ្នក ស្នើសុំឱ្យមានការវាយតម្លៃលើការអប់រំពិសេស ចំពោះកូនអ្នក
2. ការដាក់ពាក្យបណ្តឹងតវ៉ាលើកទីមួយ របស់អ្នក ជាមួយនឹង ក្រសួងអប់រំ នៃរដ្ឋមីណេសូតា (MDE)  នៅក្នុងឆ្នាំសិក្សាមួយ
3. ការស្នើសុំធ្វើសវនាការតាមទម្រង់ច្បាប់ លើកទីមួយរបស់អ្នក ឬរបស់មណ្ឌលសិក្សាស្រុក នៅក្នុងឆ្នាំសិក្សាមួយ
4. ចំពោះកាលបរិច្ឆេទ ដែលមណ្ឌលសិក្សាស្រុក សម្រេចប្តូរការដាក់កូនអ្នកឱ្យចូល រៀន ដោយការយក កូនអ្នកចេញពីសាលា ចំពោះការរំលោភវិន័យ មណ្ឌលសិក្សាស្រុក ឬ
5. តាមការស្នើសុំរបស់អ្នក ។

## ការជូនដំណឹងជាមុនជាលាយលក្ខណ៍អក្សរ

មណ្ឌលសិក្សាស្រុកត្រូវ ឱ្យអ្នកនូវសេចក្តីជូនដំណឹងជាមុន រាល់ពេល ដែលគេ ស្នើសុំចំពោះការផ្តួចផ្តើម ឬផ្លាស់ប្តូរ ឬបដិសេធមិនព្រមផ្តួចផ្តើម ឬមិនផ្លាស់ប្តូរ នូវ :

- អត្តសញ្ញាណកម្មរបស់កូនអ្នក

- ការវាយតម្លៃ និងការដាក់ឈ្មោះកូនអ្នកឱ្យចូលរៀននៅថ្នាក់ណាមួយ
- ការផ្តល់ឱ្យនូវការអប់រំសាធារណៈសមរម្យមិនបាច់បង់ប្រាក់ (FAPE) ចំពោះកូនអ្នក ឬ
- ពេលដែលអ្នកបញ្ឈប់ការយល់ព្រម ចំពោះការទទួលសេវា សំរាប់ កូនអ្នក ជាលាយលក្ខណ៍អក្សរ និងនៅមុនពេលដែលមណ្ឌលសិក្សា ស្រុកឈប់ផ្តល់សេវាអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ ដល់កូនអ្នក ។

សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ នេះត្រូវ រួមបញ្ចូលនូវ :

1. ការរៀបរាប់អំពីសកម្មភាពមួយដែលបានស្នើសុំ ឬបានបដិសេធ ដោយមណ្ឌលសិក្សាស្រុក
2. ការពន្យល់អំពីមូលហេតុដែលមណ្ឌលសិក្សាស្រុកបានស្នើឡើង ឬបានបដិសេធមិនធ្វើសកម្មភាព
3. ការរៀបរាប់អំពីទម្រង់ការវាយតម្លៃ ការប៉ាន់ប្រមាណ កំណត់ត្រា ឬរបាយការណ៍ នីមួយៗ ដែលមណ្ឌលសិក្សាស្រុកបានប្រើ ជាគោល សំរាប់ការស្នើសុំ ឬការបដិសេធរបស់ខ្លួន
4. សេចក្តីថ្លែងមួយថា អ្នកមានការការពារ ក្នុងនាមជាមាតាបិតារបស់កុមារពិការ យោងទៅតាមទម្រង់ការការពារទាំងនេះ រួមនិងព័ត៌មានអំពីរបៀបដែលអ្នកអាចបានទទួលខិត្តប័ណ្ណថតចំលងមួយច្បាប់ ដែលរៀបរាប់អំពីទម្រង់ការការពារ
5. ប្រភពព័ត៌មានសម្រាប់អ្នកទំនាក់ទំនង ដើម្បីបានទទួលជំនួយ ក្នុងការយល់បាននូវទម្រង់ការការពារនេះ
6. ការពណ៌នាអំពីជំរើសផ្សេងទៀត ដែលក្រុម IEP បានពិចារណា ព្រមទាំងមូលហេតុដែលនាំមកនូវការបដិសេធលើជម្រើស ទាំងអស់នោះ និង
7. ការពណ៌នាអំពីកត្តាផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងសំណើ ឬការបដិសេធ របស់មណ្ឌលសិក្សាស្រុក។

លើសពីអ្វីដែលជាភាពតម្រូវរបស់សហព័ន្ធ សេចក្តីជូនដំណឹងជាមុន ជាលាយលក្ខណ៍អក្សរត្រូវតែមានបញ្ជាក់ប្រាប់អ្នកថា មណ្ឌលសិក្សាស្រុក នឹងដំណើរការចំពោះសំណើរបស់ខ្លួនលើការដាក់ឱ្យកូនអ្នកចូលរៀនក្នុងសាលាណាមួយ ឬសំរាប់ការផ្តល់សេវាអប់រំពិសេស លើកលែងតែការដាក់ឱ្យកូនអ្នកចូលរៀនជាដំបូង ទៅក្នុងថ្នាក់ការអប់រំពិសេស បើអ្នកមិនបានផ្តល់ដំណឹងដល់មណ្ឌលសិក្សាស្រុក ចំពោះការជំទាស់របស់អ្នក ក្នុងរវាង 14ថ្ងៃ គិតចាប់ពីថ្ងៃដែលមណ្ឌលសិក្សាស្រុកបញ្ជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់អ្នក ។ មណ្ឌលសិក្សាស្រុក ក៏ត្រូវតែផ្តល់ឱ្យអ្នកផងដែរនូវសំណៅថតចម្លងនៃ IEP ដែលបានស្នើឡើង នៅពេលណាដែលមណ្ឌលសិក្សាស្រុកស្នើសុំ ដើម្បីធ្វើការផ្តួចផ្តើម ឬស្នើសុំធ្វើការ ប្រែប្រួលចំពោះអត្ថន័យក្នុង IEP ។

លិខិតជូនដំណឹងជាមុនជាលាយលក្ខណ៍អក្សរ ក៏មាននិយាយផងដែរថា បើអ្នកជំទាស់ ចំពោះការស្នើសុំ ឬការបដិសេធណាមួយដែលមានចែងនៅក្នុងលិខិតជូនដំណឹងជាមុន ជាលាយលក្ខណ៍អក្សរ អ្នកត្រូវតែមាន ឱកាសសម្រាប់ការប្រជុំសម្រុះសម្រួល ហើយ មណ្ឌលសិក្សាស្រុកត្រូវតែផ្តល់ដំណឹងដល់អ្នក នូវទម្រង់ការដោះស្រាយជម្លោះ ដោយ វិធីផ្សេងៗដោយរួមទាំងការដោះស្រាយដោយមានអាជ្ញាកណ្តាល និងការប្រជុំក្រុម IEP ដោយមានការសម្របសម្រួលមួយ ក្រោមឧបញ្ញត្តិរបស់រដ្ឋមីណេសូតា ផ្នែកទី 125A.091 អនុផ្នែកទី 7-9 ។

## សំរាប់ព័ត៌មានបន្ថែម

បើអ្នកត្រូវការជំនួយ ក្នុងការយល់ដឹងអំពីសិទ្ធិរបស់អ្នកនៅក្នុង ទម្រង់ការនេះ ឬ បញ្ហាណាមួយ អំពីការអប់រំរបស់កូនអ្នក សូមទាក់ទងនាយកផ្នែកការអប់រំពិសេសនៅក្នុងមណ្ឌលសិក្សាស្រុករបស់អ្នក ឬបុគ្គលដែលមានរាយឈ្មោះក្នុងបញ្ជីខាងក្រោម ។ ដំណឹងនេះ ត្រូវតែផ្តល់ឱ្យអ្នក ក្នុងទ្រង់ទ្រាយជាភាសាកំណើតរបស់អ្នក ឬតាមទ្រង់ទ្រាយសម្រាប់ ទំនាក់ទំនងផ្សេងទៀតដែលអាចប្រើប្រាស់ ។ បើទ្រង់ទ្រាយទំនាក់ទំនងរបស់អ្នក មិនមែនជាភាសាសរសេរទេ មណ្ឌលសិក្សាស្រុកត្រូវតែ ចាត់ចែង ឱ្យមានការបកប្រែឱ្យអ្នកដោយផ្ទាល់មាត់ ឬដោយមធ្យោបាយផ្សេងទៀត ។ មណ្ឌលសិក្សាស្រុក ត្រូវធានាថាអ្នកយល់អំពីខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ហើយរក្សានូវភស្តុតាង ជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ថាសេចក្តីជូនដំណឹងនេះ ត្រូវបានផ្តល់ឱ្យអ្នក ក្នុងទ្រង់ទ្រាយទំនាក់ទំនងមួយដែលថាអ្នកអាចយល់បានអំពី សេចក្តីជូនដំណឹងនេះ។

ប្រសិនបើអ្នកមានចម្ងល់អ្វីមួយ ឬអ្នកត្រូវការព័ត៌មានបន្ថែម សូមទំនាក់ ទំនងមកកាន់ :

ឈ្មោះ ________________________________

លេខទូរសព្ទ ________________________________

សំរាប់ព័ត៌មានបន្ថែម អ្នកអាចទំនាក់ទំនងអង្គការណាមួយ ដូចខាងក្រោម :

ARC Minnesota (ការតស៊ូមតិជនពិការមីណេសូតា)
www.thearcofminnesota.org
651-523-0823
1-800-582-5256

Minnesota Association for Children's Mental Health (សមាគមន៍មីណេសូតាដើម្បីសុខភាពផ្លូវចិត្តកុមារ)
www.macmh.org
651-644-7333
1-800-528-4511

Minnesota Disability Law Center (មជ្ឈមណ្ឌលច្បាប់ជនពិការមីណេសូតា)
www.mndlc.org
612-334-5970 (Twin Cities Metro) [ធ្វិនស៊ីធីម៉េត្រូ]
1-800-292-4150 (Greater Minnesota) [គ្រីធឺមីណេសូតា]
612-332-4668 (TTY) [ហៅដោយចុចជាអក្សរ]

PACER (Parent Advocacy Coalition for Educational Rights – សម្ព័ន្ធតស៊ូមតិមាតាបិតាដើម្បីសិទ្ធិអប់រំ)
www.pacer.org
952-838-9000
1-800-53-PACER,
952-838-0190 (TTY) [ហៅដោយចុចជាអក្សរ]

Minnesota Department of Education (ក្រសួងអប់រំរដ្ឋមីណេសូតា)
www.education.state.mn.us
651-582-8689
651-582-8201 (TTY) [ហៅដោយចុចជាអក្សរ]

## លិខិតអេឡិចត្រូនិច

ប្រសិនបើមណ្ឌលសិក្សាស្រុករបស់អ្នក ផ្តល់នូវជម្រើសដល់មាតាបិតា លើវិធី ដែល ត្រូវទទួលសេចក្តីជូនដំណឹង តាមលិខិតអេឡិចត្រូនិច អ្នកអាចជ្រើសរើស វិធីសម្រាប់ទទួលនូវលិខិតជូនដំណឹងជាមុនជាលាយលក្ខណ៍អក្សរ សេចក្តីជូនដំណឹងអំពីទម្រង់ការការពារ ឬសេចក្តីជូនដំណឹងពាក់ព័ន្ធនឹងបណ្តឹងសវនាការ តាមរយៈលិខិតអេឡិចត្រូនិចបាន។

## ការយល់ព្រមពីមាតាបិតា

### និយមន័យអំពីពាក្យថា ការយល់ព្រម

ការយល់ព្រមមានន័យថា អ្នកបានទទួលដំណឹង យ៉ាងពេញលេញនូវព័ត៌មានទាំងអស់ទាក់ទងនឹងសកម្មភាពដែល គេទន្ទឹងចាំការយល់ព្រមរបស់អ្នក ជាភាសាកំណើតរបស់អ្នកក៏បាន ឬតាមវិធីប្រាស្រ័យទាក់ទងផ្សេងទៀតក៏បាន ។ ដើម្បីផ្តល់ការ យល់ព្រម អ្នកត្រូវតែយល់ និងយល់ព្រម ជាលាយលក្ខណ៍អក្សរ ចំពោះការអនុវត្តន៏សកម្មភាព ដែលគេទន្ទឹងចាំការយល់ព្រមរបស់អ្នក ។ ការយល់ព្រម ជាលាយលក្ខណ៍អក្សរនេះ ត្រូវតែសរសេរ ចូលនូវកំណត់ត្រាណាមួយដែលត្រូវបញ្ចេញ និងបញ្ចេញទៅឱ្យអ្នកណា ។

### ការដកការយល់ព្រមមកវិញ

ការផ្តល់ការយល់ព្រម គឺជា ការស្ម័គ្រចិត្ត ហើយអាចដកហូតមកវិញ ជាលាយ លក្ខណ៍អក្សរបានគ្រប់ពេលវេលា ។ ទោះជាយ៉ាងណាក៏ដោយ ការដកហូតមកវិញ មិនមែនជាប្រតិសកម្មឡើយ គឺ មានន័យថាការដកហូតមកវិញនូវការយល់ព្រម មិនមែនបដិសេធ លើរាល់សកម្មភាពទាំងឡាយណាដែលបាន កើតឡើងរួចមកហើយ ក្រោយពីអ្នកបានធ្វើការយល់ព្រមរួចមកហើយ ព្រមទាំងនៅមុនពេលដែលការយល់ព្រមនេះ ត្រូវដកហូតមកវិញនោះទេ ។

### ពេលដែលមណ្ឌលសិក្សាស្រុក ត្រូវតែបានទទួលនូវការយល់ព្រមរបស់អ្នក

#### *ក. នៅមុនពេលការវាយតម្លៃដំបូង*

មណ្ឌលសិក្សាស្រុក ត្រូវតែបានទទួលការយល់ព្រមជាលាយ លក្ខណ៍អក្សរ ពីអ្នក នៅមុនពេលចាប់ផ្តើមការវាយតម្លៃដំបូងរបស់ខ្លួនចំពោះកូនអ្នក ។ អ្នក ឬមណ្ឌលសិក្សាស្រុក អាចផ្តួចផ្តើមការស្នើសុំ ដើម្បីធ្វើការ វាយតម្លៃដំបូង ។ បើអ្នកមិនឆ្លើយតប ចំពោះការស្នើសុំសេចក្តីយល់ព្រម ឬមួយបើអ្នកបដិសេធក្នុងការផ្តល់សេចក្តី យល់ព្រមចំពោះការវាយតម្លៃដំបូង មណ្ឌលសិក្សាស្រុកមិនអាចទាត់ចោល នូវការជំទាស់របស់អ្នកឡើយ ។ ការវាយតម្លៃដំបូង នឹងត្រូវតែធ្វើឡើង ក្នុងរវាង 30ថ្ងៃ នៃថ្ងៃសិក្សាដោយគិតចាប់ពីថ្ងៃដែលមណ្ឌលសិក្សាស្រុក បានទទួលការអនុញ្ញាតពីអ្នក ដើម្បីធ្វើការវាយតម្លៃ ប្រសិនបើមិនមានសំណើ សុំធ្វើការប្រជុំសម្រុះសម្រួល ឬមិនមានដំណឹងណាមួយមកកាន់មណ្ឌលទេនោះ ។

មណ្ឌលសិក្សាស្រុកនឹងមិនត្រូវបានគេចាត់ទុកថាបានប្រព្រឹត្តរំលោភ លើការ បំពេញកាតព្វកិច្ចស្វែងរកកុមាររបស់ខ្លួន ឬក៏ កាតព្វកិច្ចរបស់ខ្លួន ក្នុងការវាយតម្លៃ ឬវាយតម្លៃឡើងវិញដល់កូនអ្នកឡើយ ប្រសិនបើអ្នកបដិសេធមិនផ្តល់ សេចក្តីយល់ព្រម ឱ្យធ្វើការ វាយតម្លៃ ឬមួយអ្នកខកខានក្នុងការឆ្លើយតបចំពោះ ការស្នើសុំសេចក្តីយល់ព្រមពីអ្នក សំរាប់ការវាយតម្លៃដំបូងចំពោះកូនអ្នក ។

បើអ្នកយល់ព្រមចំពោះការវាយតម្លៃដំបូង ការយល់ព្រមនេះ មិនអាចមាន ន័យថាជាការយល់ព្រមចំពោះការផ្តល់ឱ្យជាដំបូង ចំពោះសេវាអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធឡើយ ។

#### *ខ. ការដាក់សិស្សឱ្យចូលរៀនដំបូង និងការផ្តល់សេវាអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ*

មណ្ឌលសិក្សាស្រុក ត្រូវតែបានទទួលនូវការយល់ព្រមជាលាយលក្ខណ៍របស់អ្នកសិន នៅមុនពេលបញ្ចូលឈ្មោះកូនអ្នកជាលើកដំបូង ឱ្យចូលរៀននៅក្នុងថ្នាក់ណាមួយនៅក្នុងកម្មវិធីការអប់រំពិសេស និងការផ្តល់ជាដំបូងនូវសេវាការអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ ចំពោះកូនអ្នក ដែលបានរកឃើញថាជាកុមារពិការ ។

បើអ្នកមិនឆ្លើយតបចំពោះការស្នើសុំសេចក្តីយល់ព្រម ឬមួយបើអ្នកបដិសេធផ្តល់សេចក្តីយល់ព្រម ចំពោះការផ្តល់ឱ្យជាលើកដំបូងនូវសេវាការអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ ចំពោះកូនអ្នក មណ្ឌលសិក្សាស្រុកមិនអាច ទាត់ចោល លើការបដិសេធជាលាយលក្ខណ៍អក្សររបស់អ្នកបានឡើយ ។

បើអ្នកបដិសេធមិនផ្តល់សេចក្តីយល់ព្រម ចំពោះការផ្តល់ជាដំបូងនូវសេវាអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ ឬមួយអ្នកខកខានមិនបានឆ្លើយតបចំពោះការស្នើសុំឱ្យផ្តល់នូវសេវាអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ គេមិន អាចចាត់ទុកថា មណ្ឌលសិក្សាស្រុកប្រព្រឹត្តរំលោភ ដោយការខកខានមិនបានផ្តល់នូវសេវាអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធសម្រាប់ កូនអ្នកបានឡើយ ចំពោះអ្វីដែលមណ្ឌលសិក្សាស្រុកបានស្នើសុំរួចហើយនោះ ។

### ***គ. ការវាយតម្លៃឡើងវិញ***

ការយល់ព្រមរបស់អ្នកតម្រូវឱ្យមាន នៅមុនពេលមណ្ឌលសិក្សាស្រុកចាប់ផ្តើម ធ្វើការវាយតម្លៃឡើងវិញចំពោះកូនអ្នក។ បើអ្នកបដិសេធមិនផ្តល់ការយល់ព្រមចំពោះការវាយតម្លៃឡើងវិញ មណ្ឌល សិក្សាស្រុកមិនអាចទាត់ចោល លើការបដិសេធជាលាយលក្ខណ៍អក្សររបស់ អ្នកបានឡើយ ។ ការវាយតម្លៃឡើងវិញនឹងត្រូវគេធ្វើឡើងក្នុង កំឡុង 30ថ្ងៃ នៃថ្ងៃសិក្សា ដោយគិតចាប់ពីថ្ងៃដែលមណ្ឌលសិក្សាស្រុកបានទទួល ការអនុញ្ញាតពីអ្នក ដើម្បីធ្វើការវាយតម្លៃ ឬក្នុងកំឡុងពេល 30ថ្ងៃ ពីការផុតសុពលភាព នៃចំនួន 14ថ្ងៃ គិតតាមប្រតិទិនដែលជាកំឡុងពេលមួយដែលអ្នកអាចបដិសេធចំពោះការវាយតម្លៃឡើងវិញដែលបានស្នើសុំរបស់មណ្ឌលសិក្សាស្រុក ។

### ***ឃ. សេវាអន្តរកាល***

ការយល់ព្រមរបស់អ្នកត្រូវឱ្យមាន នៅមុនពេលដែលព័ត៌មានអំពីអត្តសញ្ញាណកម្មរបស់កូនអ្នក ត្រូវបានបញ្ចេញទៅឱ្យមន្ត្រី នៃភ្នាក់ងារនានាដែលចូលរួមផ្តល់សេវាអន្តរកម្ម ឬជួយថវិកា ចំពោះការចំណាយលើសេវាអន្តរកម្ម។

### ***ពេលដែលមិនតម្រូវឱ្យមានការយល់ព្រមរបស់អ្នក***

លើកលែងតែការវាយតម្លៃជាដំបូង និងការដាក់ឈ្មោះឱ្យកូនអ្នកចូលរៀនដំបូង ព្រមទាំងការផ្តល់ សេវាអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ ប្រសិនបើអ្នកមិនផ្តល់ដំណឹងដល់មណ្ឌលសិក្សាស្រុក អំពីការបដិសេធរបស់អ្នក ក្នុងរវាង 14ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលមណ្ឌលសិក្សាស្រុកបានផ្ញើសេចក្តីជូនដំណឹងអំពីការស្នើសុំសកម្មភាព របស់ខ្លួន មកឱ្យអ្នក សំណើសុំរបស់មណ្ឌលសិក្សា ស្រុក នឹងចូលជាធរមាន បើទោះបីជាគ្មានការយល់ព្រមពីអ្នកក៏ដោយ ។

លើសពីនេះ គឺមិនចាំបាច់មានការយល់ព្រមពីអ្នកឡើយ សម្រាប់មណ្ឌលសិក្សាស្រុក ក្នុងការពិនិត្យមើលទិន្នន័យដែលមានស្រាប់ នៅក្នុងសំណុំឯកសារអប់រំរបស់កូនអ្នក ដែលជាផ្នែកមួយនៃការវាយតម្លៃ ឬផ្នែកមួយនៃការវាយតម្លៃឡើងវិញ។

ការយល់ព្រមរបស់អ្នក ក៏មិនចាំបាច់មានផងដែរ សំរាប់មណ្ឌលសិក្សាស្រុក ក្នុងការធ្វើការប្រឡង ឬធ្វើការវាយតម្លៃផ្សេងទៀត ដែលកុមារទាំងឡាយត្រូវចូលរួម ប្រសិនបើច្បាប់មិនតម្រូវឱ្យមានការយល់ព្រមពីមាតាបិតាទាំងអស់ទេនោះ។

### **សិទ្ធិរបស់មាតាបិតា ក្នុងការបដិសេធ និងសិទ្ធិចំពោះការប្រជុំសម្រុះសម្រួល**

អ្នកមានសិទ្ធិក្នុងការបដិសេធ ចំពោះសកម្មភាពណាមួយដែលមណ្ឌលសិក្សាស្រុក បានស្នើឡើងក្នុងរវាង 14ថ្ងៃ គិតតាមប្រតិទិន ដោយចាប់រាប់ពីថ្ងៃដែលមណ្ឌលសិក្សាស្រុកបានផ្ញើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ប្រាប់អ្នកអំពីសកម្មភាពដែលបានស្នើរបស់ពួកគេ ។ បើអ្នក ជំទាស់ចំពោះសំណើរបស់មណ្ឌលសិក្សាស្រុក អ្នកមានសិទ្ធិស្នើសុំធ្វើការប្រជុំសម្រុះសម្រួល ការរកដំណោះស្រាយដោយ មានអាជ្ញាកណ្តាល និងការប្រជុំក្រុម IEP ដែលមានការសម្របសម្រួល ឬស្នើសុំធ្វើសវនាការតាមច្បាប់ ។ ក្នុងរវាងដប់ថ្ងៃ តាមប្រតិទិន ដោយគិត ចាប់ពីពេលដែលមណ្ឌលសិក្សាស្រុក បានទទួលការជូនដំណឹង អំពីការជំទាស់ របស់អ្នក លើសំណើសកម្មភាព ឬបានទទួលដំណឹងអំពី ការបដិសេធ របស់ពួកគេ ចំពោះការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន មណ្ឌលសិក្សាស្រុក នឹងសុំ ឱ្យអ្នកមកចូលរួមការប្រជុំសម្រុះសម្រួលមួយ។

លើកលែងតែករណីដែលមានចែងនៅក្នុងខបញ្ញត្តិរបស់រដ្ឋមីណេសូតា ត្រង់ផ្នែកទី 125A.091 ការពិភាក្សាគ្នាទាំងអស់ ដែលត្រូវធ្វើឡើង ក្នុងកំឡុងពេលនៃការប្រជុំសម្រុះសម្រួល ត្រូវចាត់ទុកជាការសម្ងាត់ ហើយមិនអនុញ្ញាត ឱ្យយកដេញដោលក្នុងដំណើរការសវនាការតាមទម្រង់ច្បាប់ឡើយ ។ ក្នុងរវាងប្រាំថ្ងៃ បន្ទាប់ពីការប្រជុំសម្រុះសម្រួលគ្នាជាចុងក្រោយ មណ្ឌលសិក្សាស្រុកត្រូវតែរៀបចំ ហើយផ្តល់ឱ្យ អ្នកនូវអនុស្សរណៈអំពីការប្រជុំសម្រុះសម្រួល ដែលរៀបរាប់អំពីការស្នើសុំជាចុងក្រោយ ចំពោះការផ្តល់សេវាដល់កូនរបស់អ្នក ។ អនុស្សរណៈ នេះគឺជាភស្តុតាង ដែលអាចយកមកប្រើបាន ចំពោះដំណើរការណាមួយដែលកើត ឡើងនាពេលក្រោយ។

មណ្ឌលសិក្សាស្រុក និងរូបអ្នក ក៏អាចយល់ព្រមដោះស្រាយបញ្ហាតាមរយៈ អាជ្ញាកណ្តាល ឬតាមរយៈការប្រជុំក្រុមនៃកម្មវិធីអប់រំបែបឯកបុគ្គល (IEP) ដែលមានការសម្របសម្រួលដើម្បីដោះស្រាយភាពមិនយល់ស្រប។ មណ្ឌលសិក្សាស្រុក ឬរូបអ្នកក៏អាចស្នើ សុំឱ្យមានសវនាការតាមទម្រង់ច្បាប់ផងដែរ (សូមអានបន្ថែមត្រង់ផ្នែកសវនា ការតាមទម្រង់ច្បាប់មិនលំអៀង នៅក្នុងឯកសារនេះ) ។ មណ្ឌលសិក្សាស្រុក ត្រូវតែបន្ត ផ្តល់ការអប់រំ ដ៏សមរម្យដល់កូនអ្នក ក្នុងកំឡុងពេល កំពុងដំណើរការសវនាការតាមទម្រង់ច្បាប់។

**ភាពសម្ងាត់ និងព័ត៌មានអត្តសញ្ញាណបុគ្គល**

ព័ត៌មានអត្តសញ្ញាណបុគ្គល គឺជាព័ត៌មានដែលមានរួមបញ្ចូលនូវ តែក៏មិនកំណត់តែចំពោះ ឈ្មោះសិស្ស ឈ្មោះមាតាបិតាសិស្ស ឬឈ្មោះសមាជិកគ្រួសារផ្សេងទៀត អាសយដ្ឋានរបស់សិស្ស ឬអាសយដ្ឋានរបស់គ្រួសារសិស្ស អង្គកំណត់អត្តសញ្ញាណបុគ្គល ដូចជាលេខសន្តិសុខសង្គមរបស់សិស្ស អត្តលេខសិស្ស ឬកំណត់ត្រាជីវមាត្ររបស់សិស្ស អង្គអត្តសញ្ញាណដោយប្រយោលផ្សេងទៀត ដូចជាថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើតរបស់សិស្ស ឈ្មោះកាលពីនៅលីវរបស់ម្តាយសិស្ស ព័ត៌មានផ្សេងទៀត ដែលអាចប្រើតែឯង ឬជាលក្ខណៈបណ្តុំ ដែលត្រូវភ្ជាប់ទៅកាន់ ឬអាចភ្ជាប់បានជាមួយ សិស្សដែលជាសាម៉ីខ្លួន ដែលអាចនឹងអនុញ្ញាតឱ្យបុគ្គលសមរម្យមួយ នៅក្នុងសាលារៀនសហគមន៍ ដែលជាអ្នកមិនបានដឹងឮ ជាលក្ខណៈបុគ្គល ចំពោះកាលៈទេសៈដែលពាក់ព័ន្ធ ដើម្បីអាចស្គាល់សិស្សបានប្រកបដោយភាពជាក់លាក់ដ៏សមហេតុផលមួយ ឬព័ត៌មានដែលស្នើសុំដោយបុគ្គល ដែលភ្នាក់ងារ ឬវិទ្យាស្ថានអប់រំ មានការជឿជាក់ដោយសមហេតុសមផលថា អាចស្គាល់អត្តសញ្ញាណរបស់សិស្ស ដែលពាក់ព័ន្ធជាមួយនឹងកំណត់ត្រាការ អប់រំរបស់ខ្លួន ។

មណ្ឌលសិក្សាស្រុក និង MDE ត្រូវតែការពារភាពសម្ងាត់នៃទិន្នន័យ ព័ត៌មាន និង កំណត់ត្រាអត្តសញ្ញាណកម្មបុគ្គលណាមួយ ដែលពួកគេប្រមូលរក្សាទុក លាតត្រដាង និងបំផ្លាញចោល ។

ជាទូទៅ ការយល់ព្រមរបស់អ្នកជាលាយលក្ខណ៍អក្សរគឺតម្រូវឱ្យមាន នៅមុន ពេលដែលមណ្ឌលសិក្សាស្រុកអាចលាតត្រដាងនូវព័ត៌មាន អត្តសញ្ញាណកម្ម ចេញពីកំណត់ត្រាការអប់រំរបស់កូនអ្នក ទៅឱ្យនរណាមួយ ដែលមិនមែនជាមន្ត្រី របស់ភ្នាក់ងារចូលរួមលើការអប់រំពិសេស ក្នុងការប្រមូល ឬប្រើព័ត៌មានដែលស្ថិត ក្រោមច្បាប់អប់រំជនពិការ (IDEA) ឬសម្រាប់គោល បំណងផ្សេង ទៀត ដែលមិនបំពេញតាមសេចក្តីតម្រូវរបស់ច្បាប់នោះ ។

ពេលដែលមិនចាំបាច់មានការយល់ព្រមពីអ្នក ចំពោះការចែករំលែកព័ត៌មាន អត្តសញ្ញាណកម្មបុគ្គល ។ ការយល់ព្រមរបស់អ្នក ឬការយល់ព្រមពីសិស្ស ដែលមានសិទ្ធិទទួលជំនួយ (សិស្សដែលមានអាយុ ១៨ឆ្នាំឡើងទៅ) មិនតម្រូវឱ្យមាននោះទេ នៅមុនពេល ដែល ត្រូវបញ្ចេញនូវព័ត៌មានអត្តសញ្ញាណបុគ្គល ដែលមាននៅក្នុងកំណត់ត្រាការអប់រំ ទៅឱ្យមន្ត្រីនៃមណ្ឌលសិក្សាស្រុក ឬមន្ត្រីក្រសួងអប់រំរបស់រដ្ឋ សម្រាប់ការបំពេញតាមសេចក្តីតម្រូវរបស់ IDEA ។

កំណត់ត្រាការអប់រំរបស់កូនអ្នក ដោយរួមទាំងកំណត់ត្រាផ្នែក វិន័យសាលា អាចផ្ទេរទៅឱ្យមន្ត្រីនៃសាលារៀន មណ្ឌលសិក្សាស្រុក ឬវិទ្យាស្ថាន អប់រំជាន់ខ្ពស់បានដោយមិនចាំបាច់មានការយល់ព្រមពីអ្នកឡើយ ប្រសិនបើកូន របស់អ្នកមាន បំណងចុះឈ្មោះចូលរៀន នៅសាលានោះ ឬចូលរៀននៅក្នុងវិទ្យាស្ថាននោះ ឬចូលរៀនក្នុងសាលាណាមួយនៅក្នុងស្រុកនោះ ។

ការលាតត្រដាងព័ត៌មានដែលធ្វើឡើងដោយគ្មានការយល់ព្រមពីអ្នកត្រូវតែ ស្របទៅតាមច្បាប់ចំពោះសិទ្ធិអប់រំគ្រួសារ និងច្បាប់ឯកជនភាព (FERPA) ។ សូមសំអាងលើ 34 C.F.R. ផ្នែកទី 99 សំរាប់ព័ត៌មានបន្ថែម លើសេចក្តីតម្រូវ នៃការយល់ព្រម ស្តីពីទិន្នន័យភាពឯកជន ក្រោមច្បាប់សហព័ន្ធ ។

**កំរងព័ត៌មាន**

កំរងព័ត៌មានរបស់កូនអ្នក អាចចែករំលែកបានដោយមិនចាំបាច់មានការយល់ព្រមពីអ្នក ។ ព័ត៌មានប្រភេទនេះ គឺជាទិន្នន័យដែលមាននៅក្នុងកំណត់ត្រាការ អប់រំរបស់កូនអ្នក ដែលជាទូទៅមិនត្រូវបានពិចារណាថាខូចខាតលើ ឬជាការប្រព្រឹត្តិរំលោភលើឯកជនភាពឡើយ បើសិនជាលាតត្រដាងនោះ ។

កំរងព័ត៌មាន មានរួមទាំង តែក៏មិនកំណត់តែលើ អាសយដ្ឋាន លេខទូរសព្ទ អាសយដ្ឋានអ៊ីម៉េល ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត ជំនាញសិក្សា កំរិតថ្នាក់ ស្ថានភាពចុះឈ្មោះចូលរៀនរបស់សិស្ស ថ្ងៃចូលរៀន ការចូលរួមក្នុងសកម្មភាពផ្លូវការ និងកីឡារបស់សាលា ទម្ងន់ និងកំពស់ នៃសមាជិកក្រុមអត្តពលកម្ម ដឺក្រេ សញ្ញាប័ត្រកិត្តិយស និងរង្វាន់ដែលទទួលបាន ភ្នាក់ងារអប់រំថ្មីៗ ឬវិទ្យាស្ថានដែលសិស្សចូលរួម និងអត្តលេខសិស្ស អត្តលេខអ្នកប្រើប្រាស់ ឬព័ត៌មានសំគាល់អត្តសញ្ញាណកម្ម ដោយឡែក ផ្សេងទៀតរបស់សិស្ស ដែលត្រូវប្រើសម្រាប់ធ្វើការប៉ាន់ប្រមាណ ឬទំនាក់ទំនងជាអេឡិចត្រូនិច ប្រសិនបើត្រឹមត្រូវតាម លក្ខណៈវិនិច្ឆ័យជាក់លាក់ណាមួយ ។ បញ្ជីឯកសារ មិនរួមបញ្ចូលនូវលេខសុវត្ថិភាព សង្គមរបស់សិស្ស ឬអត្តលេខរបស់សិស្ស ដែលមិនប្រើ សំរាប់ចូលមើល ឬទំនាក់ទំនងជាអេឡិចត្រូនិច ដូចមានផ្តល់ជូន ក្រោមច្បាប់ របស់សហព័ន្ធ។

មណ្ឌលសិក្សាស្រុក ត្រូវតែផ្តល់ឱ្យអ្នកនូវជម្រើស ដើម្បីបដិសេធ ក្នុងការអនុញ្ញាត ឱ្យមណ្ឌលសិក្សាស្រុក កំណត់នូវទិន្នន័យណាមួយ ឬទិន្នន័យទាំងអស់ អំពីកូន របស់អ្នក ជាបញ្ជីកំណត់ត្រា ។ ការជូនដំណឹងនេះ អាចផ្តល់ឱ្យអ្នកដោយ មធ្យោបាយណាមួយដែលសមរម្យ ដើម្បីផ្តល់ដំណឹងដល់អ្នក ឬសិស្សដែលមាន សិទ្ធិទទួលសិទ្ធិនេះ ។ បើអ្នក

មិន បដិសេធក្នុងការលាតត្រដាងនូវព័ត៌មានខាងលើ ជាបញ្ជីកំណត់ត្រាទេ ព័ត៌មាន នោះ ត្រូវបានគេចាត់ទុកថា ជាទិន្នន័យសាធារណៈ ហើយអាចចែករំលែកដល់អ្នកដទៃ ដោយមិនចាំបាច់មាន ការយល់ព្រមពីអ្នកឡើយ ។

ទិន្នន័យអំពីអ្នក (មានន័យថាមាតាបិតាសិស្ស) គឺជាទិន្នន័យឯកជន តែអាចចាត់ទុកជាបញ្ជី កំណត់ត្រាបាន ប្រសិនបើមណ្ឌលសិក្សាស្រុកប្រើទម្រង់ការដូចគ្នា ដែលត្រូវប្រើក្នុងការ កំណត់ ទិន្នន័យសិស្ស ថាជាបញ្ជីទិន្នន័យ ដែលនឹងមកតាមក្រោយ ។

## ដំណឹងប្រចាំឆ្នាំជាលាយលក្ខណ៍អក្សរដែលទាក់ទងទៅនឹង ការបង់ថ្លៃដោយភាគីទីបីលើសេវា ពាក់ព័ន្ធនឹងសុខភាពដែលមានចែងនៅក្នុង IEP

មុនពេលផ្ញើប័ណ្ណទារប្រាក់ចំពោះជំនួយវេជ្ជសាស្ត្រ ឬប័ណ្ណទារប្រាក់ចំពោះកម្មវិធីថែទាំសុខភាពរបស់ រដ្ឋមីណេសូតា (MinnesotaCare) សម្រាប់ទារប្រាក់ការបង់ថ្លៃជាលើកដំបូង ចំពោះសេវាកម្មដែលពាក់ព័ន្ធ និងប្រចាំឆ្នាំនីមួយៗមណ្ឌលសិក្សាស្រុក ត្រូវតែផ្តល់ដំណឹងដល់អ្នក ជាលាយលក្ខណ៍ អក្សរ ថា ៖

1. មណ្ឌលសិក្សាស្រុក នឹងចែករំលែកទិន្នន័យពាក់ព័ន្ធនឹងកូនរបស់អ្នក និងសេវាកម្មពាក់ព័ន្ធនឹងសុខភាពដែលកូនអ្នកបានទទួល ឱ្យអ្នកបានដឹងនៅក្នុង IEP របស់កូនអ្នក ជាមួយនឹងនាយកដ្ឋានបម្រើសេវាកម្មពលរដ្ឋប្រចាំរដ្ឋមីណេសូតា (Minnesota Department of Human Services) ដើម្បីរកឱ្យ ឃើញថាតើកូនរបស់អ្នកបានស្ថិតក្រោមការធានារ៉ាប់រងសុខភាពពីកម្មវិធីជំនួយវេជ្ជសាស្ត្រ ឬ MinnesotaCare (មីណេសូតាឃែរ) ដែរឬទេ ហើយថាតើប័ណ្ណទារប្រាក់ថ្លៃសេវាកម្ម ត្រូវផ្ញើទៅកាន់ ជំនួយវេជ្ជសាស្ត្រ ឬក៏ MinnesotaCare ។

2. មុនពេលផ្ញើប័ណ្ណទារប្រាក់ទៅកាន់ជំនួយវេជ្ជសាស្ត្រ ឬ MinnesotaCare សម្រាប់សេវាកម្មថ្លៃសេវាកម្មនានាពាក់ព័ន្ធនឹងសុខភាពជាលើកដំបូង មណ្ឌលសិក្សាស្រុក ត្រូវតែបានទទួលការយល់ព្រមពីអ្នកជាមុន ដោយរួមទាំងព័ត៌មានបញ្ជាក់អំពីអត្តសញ្ញាណកម្មបុគ្គល ដែលគេអាចយកទៅ លាតត្រដាងដល់ អ្នកដទៃ (ដូចជា កំណត់ត្រា ឬព័ត៌មានអំពីសេវាកម្មដែលបានផ្តល់ដល់កូនអ្នក) គោលបំណងនៃការលាតត្រដាងព័ត៌មាននេះ ដល់ភ្នាក់ងារដទៃ (ដូចជា នាយកដ្ឋាន សេវាកម្មបម្រើសេវាពលរដ្ឋ) ហើយដែលបញ្ជាក់ថាអ្នកបានយល់ និងយល់ព្រមថា មណ្ឌលសិក្សាស្រុកអាចបើកមើលនូវអត្ថប្រយោជន៍សាធារណៈ ឬការធានារ៉ាប់ រងសម្រាប់ចំនាយលើសេវា ពាក់ព័ន្ធនឹងសុខភាពរបស់អ្នក (ឬរបស់កូនអ្នក) ។

3. មណ្ឌលសិក្សាស្រុកនឹងផ្ញើប័ណ្ណទារប្រាក់ជំនួយសុខភាព ឬប័ណ្ណទារប្រាក់ MinnesotaCare ដល់អ្នកចំពោះសេវាកម្មពាក់ព័ន្ធនឹងសុខភាព ដែលមាននៅក្នុង IEP របស់កូនអ្នក ។

4. មណ្ឌលសិក្សាស្រុកអាចមិនតម្រូវឱ្យអ្នកចុះបញ្ជី ឬចុះឈ្មោះចូលក្នុងជំនួយវេជ្ជសាស្ត្រ ឬ MinnesotaCare ឬជំនួយពីកម្មវិធីធានារ៉ាប់រងសុខភាពដទៃទៀត ដើម្បីឱ្យកូនរបស់អ្នកអាចបានទទួលសេវាកម្មការអប់រំពិសេសឡើយ ។

5. មណ្ឌលសិក្សាស្រុក អាចមិនតម្រូវឱ្យអ្នកត្រូវចំណាយប្រាក់ចេញពីហោប៉ៅរបស់ខ្លួន ដូចជាការចំណាយនូវចំនួនដែលត្រូវកាត់ចេញពីវិក្កយប័ត្រ ឬចំនួននៃ ការចំណាយរួមគ្នាដែលបានកើតឡើង ក្នុងការដាក់ពាក្យទាមទារនូវសេវាកម្មសុខភាពដែលកូនអ្នកបានទទួល តែនឹងបង់នូវតម្លៃដែលអ្នកត្រូវបង់ ។

6. មណ្ឌលសិក្សាស្រុកអាចមិនប្រើអត្ថប្រយោជន៍ដែលកូនរបស់អ្នកបានទទួលក្រោមជំនួយវេជ្ជសាស្ត្រ ឬជំនួយ MinnesotaCare ឡើយ ប្រសិនបើការប្រើនោះត្រូវ ៖ កាត់បន្ថយនូវការគ្របដណ្តប់លើការធានារ៉ាប់រងសុខភាពមួយជីវិត ឬកាត់បន្ថយអត្ថប្រយោជន៍ដទៃណាមួយពីការធានារ៉ាប់រង ត្រូវកើតចេញពីក្នុងការចំណាយរបស់គ្រួសារអ្នកសម្រាប់ការចំណាយលើសេវាកម្ម ដែលបើមិនដូច្នោះទេត្រូវគ្របដណ្តប់ដោយអត្ថប្រយោជន៍សាធារណៈ ឬកម្មវិធីធានារ៉ាប់រងដទៃ ហើយដែលតម្រូវឱ្យមានសម្រាប់កូនអ្នកពេលស្ថិតនៅក្រៅម៉ោងរៀន ត្រូវធ្វើឱ្យកើនឡើងនូវការបង់សរុបរបស់អ្នកលើការធានារ៉ាប់រងសុខភាព ឬនាំទៅរកការមិនបន្តនូវអត្ថប្រយោជន៍ ឬការធានារ៉ាប់រងណាមួយ ឬនាំឱ្យមានហានិភ័យចំពោះការបាត់សិទ្ធិរបស់អ្នកចំពោះការបោះបង់ផ្ទះ ឬសហគមន៍ជាមូលដ្ឋាន ដោយសំអាងលើការចំណាយសរុបពាក់ព័ន្ធនឹងការថែទាំសុខភាព ។

7. អ្នកមានសិទ្ធិដើម្បីបានទទួលនូវសំណៅមួយច្បាប់នៃកំណត់ត្រាការអប់រំរបស់កូនអ្នកដែលមណ្ឌលសិក្សាស្រុកយកទៅចែករំលែកដល់ភាគីទីបីណាមួយសម្រាប់ស្វែងរកការទទួលប្រាក់ដែលខ្លួនបានចំណាយមកវិញ សម្រាប់ការចំណាយណាពាក់ព័ន្ធនឹងសេវាកម្មថែទាំសុខភាពដែលមាននៅក្នុង IEP ។

អ្នកមានសិទ្ធិដើម្បីបញ្ឈប់ការយល់ព្រមរបស់អ្នកចំពោះការលាតត្រដាងកំណត់ត្រាអប់រំកូនរបស់អ្នកដល់ភាគីទីបី ដោយភាគីទីបីនោះមានរួមទាំង នាយកដ្ឋានសេវាកម្ម បម្រើពលរដ្ឋ បានគ្រប់ពេលវេលាទាំងអស់ ។ បើអ្នកបញ្ឈប់ការយល់ព្រមនេះ មណ្ឌលសិក្សាស្រុកនឹងមិនចែករំលែកនូវកំណត់ត្រាការអប់រំរបស់កូនអ្នកដើម្បីផ្ញើប័ណ្ណទារប្រាក់សម្រាប់សេវាកម្មពាក់ព័ន្ធនឹងការថែទាំសុខភាពដែលមានចែងក្នុង IEP ដល់ភាគីទីបីទៀតឡើយ ។ អ្នកអាចដកហូតមកវិញនូវការយល់ព្រមរបស់ខ្លួនបានគ្រប់ពេលវេលាទាំងអស់ ហើយសេវាកម្ម IEP របស់កូនអ្នកនឹងមិនមានការប្រែប្រួល ឬត្រូវបញ្ឈប់ឡើយ ។

## ការវាយតម្លៃជាឯករាជ្យលើការអប់រំ

ការវាយតម្លៃជាឯករាជ្យលើការអប់រំ (IEE) គឺជាការវាយតម្លៃមួយ ដែល ធ្វើឡើងដោយ បុគ្គលដែលមានលក្ខណៈសម្បត្តិ ដែលមិនមែនជាបុគ្គលិក នៃមណ្ឌលសិក្សាស្រុករបស់អ្នក។ អ្នកអាចសុំឱ្យធ្វើ IEE ដោយ មណ្ឌលសិក្សាស្រុកជាអ្នកចំណាយ បើអ្នកមិន យល់ព្រមជាមួយ ការវាយតម្លៃ របស់មណ្ឌលសិក្សាស្រុក។ មន្ត្រីសវនាការតាមទម្រង់ច្បាប់ ក៏អាចបញ្ជាឱ្យមាន ការវាយតម្លៃលើការអប់រំ ជាឯករាជ្យសម្រាប់ កូនរបស់អ្នក ដោយមណ្ឌលសិក្សាស្រុកជាអ្នកចេញថ្លៃចំណាយ ក្នុងពេលដំណើរការធ្វើសវនាការតាមទម្រង់ ច្បាប់។

ក្នុងពេលសុំធ្វើ IEE មណ្ឌលសិក្សាស្រុក ត្រូវតែផ្ដល់ឱ្យអ្នកនូវព័តិមាន អំពីលក្ខណៈវិនិច្ឆ័យរបស់ខ្លួន សំរាប់ការជ្រើសរើស មេប្រយោគ ឯករាជ្យ និងព័តិមាន អំពីទីកន្លែងដែលគេអាចទទួលការធ្វើការវាយតម្លៃជា ឯករាជ្យលើការអប់រំ។

បើអ្នកស្នើសុំធ្វើ IEE មណ្ឌលសិក្សាស្រុក ដោយគ្មានការពន្យារ ត្រូវតែធានាថា គឺជាការធ្វើឡើងដោយស្ថិតក្រោមការចំណាយរបស់រដ្ឋ ឬស្នើសុំ សវនាការតាម ទម្រង់ច្បាប់ឱ្យកំណត់ពីភាពសមរម្យ លើការវាយតម្លៃរបស់ខ្លួន។ ប្រសិនបើ មណ្ឌលសិក្សាស្រុកចូលសវនាការតាមទម្រង់ ច្បាប់ ហើយមន្ត្រីសវនាការតាមទម្រង់ច្បាប់ រកឃើញថា ការវាយតម្លៃ របស់មណ្ឌលសិក្សាស្រុក មានភាពសមរម្យ អ្នកក៏នៅតែមានសិទ្ធិ សុំឱ្យមានការ វាយ តម្លៃដោយឯករាជ្យដដែល តែមិនមែនស្ថិតក្រោម ការចំណាយ របស់រដ្ឋឡើយ។

បើអ្នកបានទទួល IEE លទ្ធផលនៃការវាយតម្លៃ ត្រូវតែយកមកពិចារណា ដោយក្រុម IEP/IIIP (Individual Interagency Intervention Plan-ផែនការអន្តរាគមន៍អន្តរភ្នាក់ងារសម្រាប់បុគ្គលម្នាក់ៗ) ហើយអាចត្រូវយក ទៅធ្វើជាភស្តុតាង នៅឯសវនាការតាមទម្រង់ច្បាប់ អំពីកូនរបស់អ្នកបាន ។

## កំណត់ត្រាការសិក្សា

### និយមន័យចំពោះកំណត់ត្រាការសិក្សា

ក្រោមច្បាប់របស់សហព័ន្ធ កំណត់ត្រាការអប់រំ មានន័យថា ជាកំណត់ត្រាទាំង ឡាយណា ដែលពាក់ព័ន្ធដោយផ្ទាល់ចំពោះសិស្ស ហើយដែលរក្សាទុកដោយ នាយកដ្ឋាន ឬមណ្ឌលសិក្សាស្រុក ។

### សិទ្ធិរបស់អ្នកចំពោះការចូលមើលកំណត់ត្រាទាំងនោះ

បើអ្នកត្រូវការមើលកំណត់ត្រាការសិក្សារបស់កូនអ្នក មណ្ឌលសិក្សាស្រុក ត្រូវតែឱ្យអ្នកបើកមើលបាន ។ កំណត់ត្រាសិក្សា មានរួមមួយភាគធំ លើព័តិមាន អំពីកូនរបស់អ្នកដែលសាលារក្សាទុក។ តែទោះជាយ៉ាងណាក៏ដោយ សម្រាប់ព័តិមានដែលគ្រូរបស់ កូនអ្នកជាអ្នករក្សាទុក សម្រាប់ យកមកប្រើការលើការបង្រៀនរបស់ខ្លួន អាចមិនមានរួមបញ្ចូល នៅក្នុងកំណត់ត្រាការសិក្សាឡើយ។

មណ្ឌលសិក្សាស្រុក ត្រូវតែអនុញ្ញាតឱ្យអ្នកមើលកំណត់ត្រាទាំងនោះ ដោយគ្មាន ការពន្យារណាមួយដែលមិនសមរម្យ និងនៅមុនពេលការប្រជុំណាមួយ ដែលនិយាយអំពី IEP ឬសវនាការណាមួយ ឬប្រជុំរកដំណោះស្រាយណាមួយ អំពីកូនរបស់អ្នក ។ លើសពីនេះទៅទៀត មណ្ឌលសិក្សាស្រុក ត្រូវតែធ្វើតាមសំណើសុំរបស់អ្នក ដើម្បីមើលកំណត់ត្រា ការអប់រំរបស់កូនអ្នក ជាបន្ទាន់ បើអាចធ្វើទៅបាន ឬក្នុងរវាង ១០ថ្ងៃ នៃការស្នើសុំ ( មិនរួមបញ្ចូលថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃសម្រាករបស់រដ្ឋ) បើសិនជាការឱ្យអ្នកមើលមិន អាចធ្វើបានភ្លាមៗទេនោះ។

សិទ្ធិរបស់អ្នក ដើម្បីពិនិត្យ និងមើលឡើងវិញលើកំណត់ត្រា មានរួមទាំងសិទ្ធិ :

1. ការពន្យល់ ឬការបកប្រែរបស់មណ្ឌលសិក្សាស្រុក អំពីកំណត់ត្រាកូន របស់អ្នក តាមការស្នើសុំ
2. សុំឱ្យតំណាងរបស់អ្នកពិនិត្យ និងមើលឡើងវិញនូវកំណត់ ត្រាអំពីកូន របស់អ្នក ជំនួសឱ្យរូបអ្នក
3. សុំឱ្យមណ្ឌលសិក្សាស្រុក ផ្ដល់ឱ្យអ្នកនូវសំណៅថតចម្លងអំពី កំណត់ត្រា កូនរបស់អ្នក និង
4. មើលឡើងវិញនូវកំណត់ត្រាអំពីកូនរបស់អ្នក តាមបំណងប្រាថ្នា របស់អ្នក ដោយមិនកំណត់ពីចំនួនដង ឱ្យតែស្របទៅតាមច្បាប់រដ្ឋ ។ ច្បាប់រដ្ឋចែងថា បើគេបង្ហាញអ្នកនូវទិន្នន័យឯកជន និងពន្យល់អ្នកអំពីអត្ថន័យរបស់វា ទិន្នន័យនោះមិនចាំបាច់ត្រូវ យកទៅ លាតត្រដាងដល់អ្នកឡើយ ក្នុងរយៈពេល ៦ខែ បើសិនជាវិវាទ ឬសកម្មភាពមួយមិនត្រូវបានដ្ឋឹបទុក ឬព័ត៌មានថ្មី ត្រូវបាន បង្កើតឡើង ឬត្រូវបានប្រមូល ទេនោះ ។

**ការផ្ទេរសិទ្ធិ**

ជាទូទៅ សិទ្ធិរបស់អ្នកក្នុងការចូលមើលកំណត់ត្រាការអប់រំរបស់កូនអ្នក ត្រូវផ្ទេរ ទៅឱ្យកូនរបស់អ្នក ពេលដែលគេមានអាយុ ១៨ឆ្នាំ ។ ត្រូវតែមាន ការជូនដំណឹងដល់អ្នក និងកូនរបស់អ្នក ចំពោះការផ្ទេរសិទ្ធិនេះ ។

**កំណត់ត្រាលើចំនួនសិស្សលើសពីមួយនាក់**

ប្រសិនបើមានកំណត់ត្រាការអប់រំណាដែលរួមបញ្ចូលនូវព័ត៌មាន របស់សិស្ស លើសពីមួយនាក់ អ្នកមានសិទ្ធិពិនិត្យ និងមើលឡើងវិញ ចំពោះតែ ព័ត៌មានណា ដែលពាក់ព័ន្ធនឹងកូនរបស់អ្នកតែប៉ុណ្ណោះ ។ អ្នក អាចស្វែងរកសិទ្ធិ ពិនិត្យ និងមើលឡើងវិញ នូវកំណត់ត្រាការអប់រំ ដែល រួមបញ្ចូលទាំង ព័ត៌មានរបស់កុមារដែលមិនមែនជាកូនរបស់អ្នកបាន តែសូមចងចាំ ថាមាតាបិតារបស់កុមារទាំងនោះ ក៏មានសិទ្ធិបដិសេធចំពោះសំណើសុំរបស់អ្នក បានដែរ ។

**បញ្ជីនៃប្រភេទ និងទីកន្លែងនៃព័ត៌មាន**

ឆ្លងតាមការស្នើសុំរបស់អ្នក មណ្ឌលសិក្សាស្រុក និងនាយកដ្ឋានអប់រំ ត្រូវតែផ្ដល់ឱ្យ អ្នកនូវបញ្ជីនៃប្រភេទ និងទីកន្លែងនៃកំណត់ត្រាការអប់រំ ដែលពួកគេប្រមូល រក្សាទុក ឬប្រើប្រាស់ ។

**សិទ្ធិបើកមើលកំណត់ត្រាដោយអ្នកដទៃ**

មណ្ឌលសិក្សាស្រុក ត្រូវតែរក្សាទុកកំណត់ត្រា សម្រាប់ការសុំមើល នីមួយៗ និងការលាតត្រដាងនីមួយៗ អំពីព័ត៌មានអត្តសញ្ញាណ កម្មបុគ្គល នៅក្នុង កំណត់ត្រាការសិក្សាអំពីកូនរបស់អ្នក ។ កំណត់ត្រា នៃការបើក មើលនេះ ត្រូវរួមទាំងឈ្មោះអ្នកសុំមើល ឬអត្តសញ្ញាណ កម្មរបស់អ្នក ដែលបានទទួល កំណត់ត្រាអំពីកូនរបស់អ្នកលើការសិក្សា ថ្ងៃបើកមើល និងបំណងនៃការលាតត្រដាងទិន្នន័យ ឬសិទ្ធិប្រយោជន៍ ស្របច្បាប់ របស់បុគ្គល នៅក្នុងព័ត៌មាននេះ ។

**ការយល់ព្រមលើការបញ្ចេញកំណត់ត្រា**

ជាទូទៅការយល់ព្រមរបស់អ្នក ត្រូវធ្វើនៅមុនពេលបញ្ចេញនូវព័ត៌មាន អត្តសញ្ញាណកម្មរបស់បុគ្គល ដល់មនុស្ស ឬអង្គការ ដែលមិនមាន សិទ្ធិបើកមើល ។ ការយល់ព្រមត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវ តែបញ្ជាក់ពីឈ្មោះបុគ្គល ឬអង្គការ ដែលមានសិទ្ធិទទួលនូវព័ត៌មាន នោះ : សភាពរបស់ព័ត៌មានដែលត្រូវលាតត្រដាង គោលបំណង ក្នុងការ យកព័ត៌មាននោះទៅប្រើ និងពេលផុតកំណត់ដែលសម ហេតុសមផល មួយ សំរាប់សិទ្ធិក្នុងការលាតត្រដាងនូវព័ត៌មាន ។ តាមការស្នើសុំមណ្ឌលសិក្សាស្រុក ត្រូវតែផ្ដល់ឱ្យអ្នកនូវសំណៅថតចម្លងនៃ កំណត់ត្រា ដែលត្រូវលាតត្រដាង ក្រោយពេលអ្នកផ្ដល់ការយល់ព្រមរួច ។

មណ្ឌលសិក្សាស្រុក អាចមិនលាតត្រដាងនូវព័ត៌មាន ដែលមាននៅក្នុង IEP/IIIP របស់កូនអ្នក ដោយទាំងព័ត៌មានការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល ដល់ក្រុម ហ៊ុនផែនការសុខភាព ដោយគ្មានហត្ថលេខា និងកាលបរិច្ឆេទផ្ដល់ការ យល់ព្រម របស់អ្នក ។

**តម្លៃនៃការស្វែងរក ការទាញយក និងការថតចម្លងនូវកំណត់ត្រា**

មណ្ឌលសិក្សាស្រុកអាចមិនទារថ្លៃស្រាវជ្រាវ ឬការដកស្រង់លើ កំណត់ត្រា ទាំងនោះឡើយ ។ ទោះជាយ៉ាងណាក៏ដោយ បើអ្នក ស្នើសុំសំណៅថតចម្លងច្រើន មណ្ឌលសិក្សាស្រុកអាចទារថ្លៃដែល សមរម្យមួយ សំរាប់ ការថតចម្លង ទាំងនោះ នេះបើការធ្វើបែបនេះ មិនបានហាមឃាត់អ្នក ពីការប្រើសិទ្ធិរបស់ខ្លួន ក្នុងការពិនិត្យមើល និងមើលឡើងវិញនូវកំណត់ត្រាការអប់រំ ដែលអ្នកមិន មានលទ្ធ ភាពចំណាយបាន ។

**ការកែប្រែនូវកំណត់ត្រា តាមការស្នើសុំរបស់មាតាបិតា**

បើអ្នកជឿថា ព័ត៌មាននៅក្នុងកំណត់ត្រាអំពីកូនអ្នក វាមិនត្រឹមត្រូវ វានាំឱ្យមាន ការបកប្រែខុស នៅមានចំណុចខ្វះខាត ឬវាប៉ះពាល់ដល់ សិទ្ធឯកជន ឬសិទ្ធិផ្សេង ទៀតរបស់កូនអ្នក អ្នកអាចស្នើសុំជាលាយ លក្ខណ៏អក្សរទៅកាន់មណ្ឌលសិក្សា ស្រុក ឱ្យធ្វើការកែប្រែ ឬលុបចោល នូវ ព័ត៌មាននោះ។ មណ្ឌលសិក្សាស្រុក ត្រូវសម្រេចដោយប្រើពេលដែលសមរម្យមួយ ថាខ្លួន ត្រូវ កែប្រែកំណត់ត្រានោះឬទេ ។ បើមណ្ឌលសិក្សាស្រុកសម្រេចមិនធ្វើ ការកែប្រែ កំណត់ត្រា គេត្រូវតែផ្តល់ដំណឹងដល់អ្នកថាអ្នកមានសិទ្ធិសុំ ធ្វើសវនាការតាមទម្រង់ច្បាប់ ដើម្បីធ្វើការតទល់ជាមួយនឹងការសម្រេចចិត្តនេះ ។ តាមលទ្ធផល នៃការធ្វើសវនា ការតាម ទម្រង់ច្បាប់ ប្រសិនបើមណ្ឌលសិក្សាស្រុកសំរេច ចិត្តថា ព័ត៌មាន នោះ មិនមែនមិនត្រឹមត្រូវទេ មិននាំឱ្យមានការបកប្រែខុសទេ ឬថាមិនរំលោភសិទ្ធិឯកជន របស់ កូនអ្នកទេ គេត្រូវផ្តល់ដំណឹងដល់ អ្នកថាអ្នកមានសិទ្ធិ ដាក់ បញ្ចូល នូវ យោបល់របស់អ្នក និងការមិនយល់ ព្រមរបស់អ្នក ជាមួយនឹង ព័ត៌មាន ដែលអ្នកចង់តទល់ នៅក្នុងកំណត់ត្រា ការសិក្សាអំពីកូន របស់អ្នក។ សវនាការតាមទម្រង់ច្បាប់មួយ ដែលត្រូវ ធ្វើដើម្បីតទល់ដើម្បីព័ត៌មានក្នុងកំណត់ត្រាការអប់រំ ត្រូវតែធ្វើឡើង ទៅតាម ទម្រង់ការ សម្រាប់សវនាការ ប្រភេទនោះដែលស្ថិតក្រោម FERPA ។

**ការផ្ទេរកំណត់ត្រា**

ខបញ្ញត្តិរបស់រដ្ឋមីណេសូតា តម្រូវឱ្យមណ្ឌលសិក្សាស្រុក សាលារៀនបង់ប្រាក់ ឬសាលាឯកជន ផ្ទេរកំណត់ត្រាការអប់រំរបស់សិស្សដែលការផ្ទេរនេះ មានរួមទាំងកំណត់ត្រាវិន័យសាលា ពីសាលាដែលសិស្សត្រូវផ្ទេរ ចេញទៅកាន់សាលាដែល សិស្សដូរទៅកាន់ ក្នុងរវាង 10ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលការស្នើសុំ ។

**ការបំផ្លាញកំណត់ត្រានានាចោល**

មណ្ឌលសិក្សាស្រុកត្រូវតែផ្តល់ដំណឹងដល់អ្នក ពេលដែលទិន្នន័យបញ្ជាក់ ពី អត្តសញ្ញាណកម្ម ឈប់យកទៅប្រើប្រាស់ទៀត សម្រាប់ផ្តល់សេវា អប់រំ ពិសេស ចំពោះកូនអ្នក ។ ព័ត៌មានទាំងនោះ ត្រូវតែ បំផ្លាញចោល តាម ការស្នើសុំរបស់អ្នក ។ ទោះជាយ៉ាងណាក៏ដោយ មណ្ឌលសិក្សាស្រុក អាចរក្សាទុកកំណត់ត្រាជាអចិន្ត្រៃយ៍អំពី ឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ ថ្នាក់ កំណត់ត្រាវត្តមាន ថ្នាក់ដែលចូលរៀន ក៏រិតថ្នាក់ រៀនចប់ និង ឆ្នាំរៀនចប់របស់កូនអ្នក ។

ក្រោមច្បាប់សហព័ន្ធ ការបំផ្លាញចោលមានន័យថា ការដកចេញជាលក្ខណៈរូប នូវអត្តសញ្ញាណបុគ្គល ចេញពីព័ត៌មាន ដើម្បីឱ្យព័ត៌មាននោះលែងមានអត្ត សញ្ញាណបុគ្គលទៀត ។ ដូច្នេះកំណត់ត្រារបស់សិស្ស មិនចាំបាច់ត្រូវបំផ្លាញចោល នូវរូបរាង តាមការស្នើសុំរបស់អ្នកឱ្យបំផ្លាញចោលកំណត់ត្រានានាដែលពាក់ព័ន្ធ នឹងការអប់រំពិសេសនោះឡើយ ។ មណ្ឌលសិក្សាស្រុក អាចធ្វើតាមសេចក្តីតម្រូវ នេះតាមការសមគួរ ដោយដកចេញនូវព័ត៌មានអត្តសញ្ញាណបុគ្គល ពីកំណត់ ត្រារបស់ សិស្ស ។ ជាទូទៅជម្រើសចំពោះវិធីក្នុងការបំផ្លាញព័ត៌មាន គឺអាស្រ័យលើមណ្ឌលសិក្សាស្រុកជាអ្នកជ្រើសរើស ។

មណ្ឌលសិក្សាស្រុក នឹងមិនបំផ្លាញកំណត់ត្រាការអប់រំណាមួយ ប្រសិន បើមាន សំណើសុំណាមួយដែលនៅមិនទាន់បានដំណើរការមើល ឬពិនិត្យឡើងវិញ នូវកំណត់ត្រានោះ។

បើទោះបីជាអ្នក ស្នើសុំឱ្យមានការបំផ្លាញចោលនូវកំណត់ត្រាការអប់រំរបស់ កូនអ្នកក៏ដោយ ក៏មណ្ឌលសិក្សាស្រុកនៅតែអាចរក្សាទុកកំណត់ត្រាចាំបាច់ មួយចំនួនដើម្បីធ្វើតាមច្បាប់ការផ្តល់ការអប់រំទូទៅ (GEPA) ដែលតម្រូវថា អ្នកដែលបានទទួលថវិការបស់សហព័ន្ធ ត្រូវរក្សាទុកនូវកំណត់ត្រា នានា ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាទាំងនោះ។ អ្នកអាចចង់រក្សាទុកនូវកំណត់ត្រា ជាក់លាក់ ចំពោះការ អប់រំពិសេស អំពីកូន របស់អ្នក ដើម្បីធ្វើជាឯកសារសំរាប់ ពេលអនាគត ដូចជាសំរាប់ការដាក់ ពាក្យសុំបេនីហ្វិត SSI ជាដើម ។

## ការសម្រុះសម្រួលដោយអាជ្ញាកណ្តាល

ការសម្រុះសម្រួលគឺជាអ្វីដែលមិនបាច់បង់ប្រាក់ឡើយ ហើយជាដំណើរការដោយស្ម័គ្រចិត្ត ដើម្បីជួយក្នុងការដោះស្រាយវិវាទ ។ អ្នក ឬមណ្ឌលសិក្សាស្រុក អាចស្នើសុំធ្វើការសម្រុះសម្រួលដែលមិនបាច់បង់ប្រាក់កម្មវិធីដោះស្រាយទំនាស់ដោយវិធីផ្សេង ពីនាយកដ្ឋានអប់រំប្រចាំរដ្ឋមីណេសូតា តាមរយៈទូរស័ព្ទលេខ 651-582-8222 ឬលេខ 1-866-466-7367 ។ ការសម្រុះសម្រួលប្រើអាជ្ញាកណ្តាលជា ភាគីទីបីដែលមានអព្យាក្រឹតភាពហើយ បានទទួលការ បណ្តុះបណ្តាលលើបច្ចេកទេស ដំណោះស្រាយវិវាទ។ ការសម្រុះសម្រួល អាចមិនត្រូវយកទៅប្រើដើម្បី បដិសេធ ឬពន្យាសិទ្ធិ របស់អ្នក ដើម្បីធ្វើសវនាការតាមទម្រង់ច្បាប់ ។ ទាំងរូបអ្នក និងមន្ត្រីរបស់មណ្ឌលសិក្សាស្រុក ត្រូវតែយល់ព្រមធ្វើការសាកល្បងសម្រុះ សម្រួល នៅមុន ពេលដែលគេអាចតែងតាំងអ្នកសម្រុះសម្រួល ។ អ្នក ឬមណ្ឌល សិក្សាស្រុក អាចសុំបញ្ចប់ការសម្រុះសម្រួលបាន គ្រប់ពេលក្នុងកំឡុងពេល ធ្វើការសម្រុះសម្រួល ។

ប្រសិនបើអ្នក និងមណ្ឌលសិក្សាស្រុក អាចដោះស្រាយបានទាំងអស់ ឬ តែមួយ ផ្នែកនៃវិវាទ ឬយល់ព្រមប្រើទម្រង់ការផ្សេងទៀត ដើម្បីដោះស្រាយវិវាទ អ្នកធ្វើជាអាជ្ញាកណ្តាល គួរធានាឱ្យបានថា ដំណោះស្រាយ ឬការព្រមព្រៀង គឺមានលក្ខណៈជាលាយលក្ខណ៍អក្សរ ហើយចុះហត្ថលេខាដោយអ្នក និងមណ្ឌល សិក្សាស្រុក ហើយភាគីទាំងពីរ ទទួលនូវសំណៅថតចម្លងនៃឯកសារនេះ ម្នាក់ មួយច្បាប់ ។ ដំណោះស្រាយ ឬកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ គួរតែ សរសេរថា ការពិភាក្សាទាំងអស់ដែលកើតឡើងក្នុងពេលធ្វើការសម្រុះសម្រួល គឺជាការសម្ងាត់ ហើយមិនអាចយកទៅ ប្រើដើម្បីធ្វើជាភស្តុតាង នៅក្នុងដំណើរ ការសវនាការតាមទម្រង់ច្បាប់ ឬការដោះស្រាយខាងផ្លូវ រដ្ឋប្បវេណី ណាមួយ បានឡើយ ។ ដំណោះស្រាយ ឬកិច្ចព្រមព្រៀង គឺជាអ្វីដែល ស្របច្បាប់ ដែលអ្នក និងមណ្ឌលសិក្សាស្រុក មិនអាចប្រព្រឹត្តរំលោភបាន ហើយអាចឱ្យតុលាការរដ្ឋ និងតុលាការស្រុករបស់សហព័ន្ធយកមកធ្វើជាឧបករណ៍ សម្រាប់អនុវត្តច្បាប់បាន ។ អ្នក ឬមណ្ឌលសិក្សាស្រុក អាចស្នើសុំធ្វើការសម្រុះសម្រួលដោយមានអាជ្ញា កណ្តាល ជាថ្មីទៀតបាន ដើម្បីដោះស្រាយវិវាទ ចំពោះការ អនុវត្តន៍ កិច្ចព្រម ព្រៀងកើត ចេញពីការសម្រុះសម្រួលកាលពីលើកមុន។

## ការដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ

អង្គការទាំងឡាយណា ឬបុគ្គលណាមួយ អាចដាក់ពាក្យបណ្តឹង ទៅកាន់ នាយកដ្ឋានអប់រំនៃរដ្ឋមីណេសូតា (MDE) ។ ពាក្យ បណ្តឹងដែលផ្ញើទៅ កាន់ MDE ត្រូវតែ :

1. ជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខាដោយបុគ្គល ឬអង្គការ ដែលជាអ្នកប្តឹង
2. ការប្រព្រឹត្តិរំលោភដែលរងការចោទប្រកាន់ ចំពោះច្បាប់ ឬបញ្ញត្តិ របស់រដ្ឋ ឬរបស់សហព័ន្ធ ចំពោះការអប់រំពិសេស
3. សរសេរអំពីឥថភាព ដែលការចោទប្រកាន់សំអាងលើ
4. រួមបញ្ចូលនូវឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទ របស់បុគ្គល ឬអង្គការ ដែលជាអ្នកប្តឹង
5. រួមបញ្ចូលនូវឈ្មោះ និងអាសយដ្ឋានផ្ទះ របស់សិស្ស និងឈ្មោះ សាលារបស់សិស្ស
6. ការពណ៌នាអំពីសភាពនៃបញ្ហារបស់សិស្ស ដោយរួមទាំង ឥថភាព ពាក់ព័ន្ធនឹងបញ្ហា
7. ដំណោះស្រាយចំពោះបញ្ហាដែលបានស្នើឡើង តាមការដឹង និងដែលភាគីនី មួយៗមាន នៅពេលដាក់ពាក្យបណ្តឹង និង
8. បញ្ជូនបន្តទៅកាន់ទីភ្នាក់ងារសាធារណៈ ដែលផ្តល់សេវា ដល់កុមារ ក្នុង ពេលជាមួយគ្នាដែល បណ្តឹងនេះបានបញ្ជូនទៅកាន់ MDE ។

ពាក្យបណ្តឹង ត្រូវផ្ញើទៅកាន់ :

Minnesota Department Education
Division of Compliance and Assistance
Due Process Supervisor
1500 West Highway 36
Roseville, MN 55113-4266
651.582.8689 ទូរសព្ទ
651.582.8725 ទូរសារ

ពាក្យបណ្តឹងនេះ ត្រូវតែមកដល់ដៃ MDE មិនលើសពីមួយឆ្នាំ ក្រោយពេល ដែលសកម្មភាពប្រព្រឹត្តិរំលោភដែលរងការចោទប្រកាន់ បានកើតឡើង ។ MDE នឹងចេញការសម្រេចចិត្តជាលាយលក្ខណ៍អក្សរ ក្នុងរវាង 60ថ្ងៃ ប្រសិនបើ មិនស្ថិតក្នុងកាលៈទេសៈពិសេស ដែល តម្រូវឱ្យមានពេលវែងជាងនេះ ឬមួយថារូបអ្នក ឬមណ្ឌលសិក្សាស្រុកយល់ព្រមពន្យារពេល ដើម្បីទៅចូលរួម ក្នុងការសម្រុះសម្រួលដែលមានអាជ្ញា កណ្តាល ទេនោះ ។ អ្នក (មាតាបិតា) ឬ មណ្ឌលសិក្សាស្រុក អាចធ្វើឧទ្ធរណ៍ ចំពោះការសម្រេចចុងក្រោយលើពាក្យ បណ្តឹងរបស់ សវនាការ ទៅកាន់ Minnesota Court of Appeals (តុលា ការឧទ្ធរណ៍របស់រដ្ឋមីណេសូតា) បាន ក្នុងរវាង 60ថ្ងៃ បន្ទាប់ពីការបាន ទទួល សេចក្តីជូនដំណឹង ពីការសម្រេចចិត្តចុងក្រោយ របស់សវនាការ ។

## បែបបទគំរូ

MDE បានបង្កើតបែបបទគំរូ ដែលអាចយកមកប្រើ ដើម្បីដាក់ពាក្យបណ្តឹង ការអប់រំពិសេស ឬដាក់បណ្តឹងសវនាការតាមទម្រង់ច្បាប់បាន ។ បែបបទទាំង នេះ មិនតម្រូវឱ្យប្រើដោយខានមិនបាននោះទេ តែវាគឺជាប្រភពធនធាន ដែល អ្នកអាចប្រើ ពេលដែលអ្នកត្រូវការដាក់ពាក្យបណ្តឹង ។ បែបបទគំរូអំពីការធ្វើសវការតាមទម្រង់ច្បាប់ទាំងនេះ អាចរក ានទៅឯគេហទំព័ររបស់ MDE ដោយការចុចលើ MDE > School Support (ការជ្រោមជ្រែងសាលា) > Compliance and Assistance (ការអនុវត្តតាម និងជំនួយ) > Due Process Forms (បែបបទសវនាការ)

## សវនាការតាមទម្រង់ច្បាប់មិនលំអៀង

ទាំងអ្នក និងមណ្ឌលសិក្សាស្រុក មានសិទ្ធិស្នើសុំឱ្យមានសវនាការតាមទម្រង់ច្បាប់មិនលំអៀង ជាលាយលក្ខណ៍អក្សរ ក្នុងរវាងពីរឆ្នាំ ដោយគិតចាប់ពីថ្ងៃ ដែលអ្នក ឬភ្នាក់ងារបានដឹង ឬដែលគួរតែបានដឹងអំពី សកម្មភាពដែលរងការ ចោទប្រកាន់ ដែលយកមកធ្វើជាគោលសម្រាប់ សវនាការ តាមទម្រង់ច្បាប់ ។

ដំណើរការសវនាការ អាចស្នើសុំបាន ដោយយោងតាមសំណើ ឬការបដិសេធ លើការផ្តួចផ្តើម ឬការប្រែប្រួល ចំពោះការវាយតម្លៃ IEP ការដាក់ឱ្យសិស្ស ចូលរៀននៅថ្នាក់ណាមួយ ឬដើម្បីផ្តល់ FAPE ។

សវានាការនេះ អាចដោះស្រាយនូវរឿងរ៉ាវណាមួយពាក់ព័ន្ធនឹង អត្តសញ្ញាណកម្ម ការវាយតម្លៃ ការដាក់ឱ្យក្មេងចូលរៀន ការប្រកាសនូវ អត្តសញ្ញាណកម្ម ឬការផ្តល់នូវការអប់រំសាធារណៈ ដែលសមរម្យ និងមិនបាច់បង់ប្រាក់ ចំពោះកូន របស់អ្នក ។ ក្នុងកំឡុងពេល 15ថ្ងៃ នៃការបានទទួលនូវការជូនដំណឹង លើសវនាការអំពីបណ្តឹងរបស់អ្នក ហើយនៅមុនពេលធ្វើសវនាការ មណ្ឌលសិក្សាស្រុកត្រូវរៀបចំឱ្យ មានការ ប្រជុំដើម្បីរកដំណោះស្រាយ ជាមួយអ្នក និងសមាជិកក្រុម IEP ដែលពាក់ព័ន្ធ ដែលបានដឹងអំពីតថភាពចំពោះការចោទប្រកាន់ នៅក្នុង បណ្តឹងសុំឱ្យមាន សវនាការ ។

គោលបំណងនៃការប្រជុំនេះ គឺសំរាប់ឱ្យអ្នកធ្វើការពិភាក្សា ពីដំណើរការសវនា ការ ព្រមទាំងតថភាពដែលបង្កើតបានជាគោល សំរាប់បណ្តឹងសុំធ្វើសវនាការ ដើម្បីឱ្យមណ្ឌលសិក្សាស្រុក មានឱកាស ដើម្បី ដោះស្រាយវិវាទ ដែលជាគោល សម្រាប់បណ្តឹងសុំធ្វើសវនាការ ។

ការប្រជុំរកដំណោះស្រាយ មិនចាំបាច់ធ្វើឡើងទេ ប្រសិនបើអ្នក និង មណ្ឌល សិក្សា ស្រុក យល់ព្រមគ្នាជាលាយលក្ខណ៍អក្សរថាបោះបង់ការប្រជុំ ឬយល់ព្រម ធ្វើការសម្រុះសម្រួលគ្នាដោយមានអាជ្ញាកណ្តាល ។ ការប្រជុំរកដំណោះស្រាយ ក៏មិនជាការតម្រូវ ឱ្យធ្វើផង ដែរ នៅពេលដែលមណ្ឌលសិក្សាស្រុក គឺជាភាគីដែលស្នើសុំធ្វើសវាការ ។

ប្រសិនបើរឿងវិវាទ មិនអាចដោះស្រាយបាន ក្នុងរវាង 30ថ្ងៃ ក្រោយពេលបាន ទទួលបណ្តឹងសុំធ្វើសវនាការ កំឡុង ពេលឡើងសវនាការ ត្រូវចាប់ផ្តើម ។

ប្រសិនបើមណ្ឌលសិក្សាស្រុក មិនអាចធ្វើឱ្យអ្នកចូលរួមបាន នៅក្នុងការ ប្រជុំរក ដំណោះស្រាយ ឬការសម្រុះសម្រួលគ្នា ក្រោយពេលធ្វើការខំ ប្រឹងប្រែងមួយដ៏ សមរម្យ រួចមក ហើយមណ្ឌលសិក្សាស្រុក ក៏មិន យល់ព្រម លើកលែង ការប្រជុំ រកដំណោះស្រាយជាលាយលក្ខណ៍អក្សរ មណ្ឌលសិក្សាស្រុក អាច ស្នើសុំមន្ត្រី សវនាការ ឱ្យទាត់ចោលបណ្តឹងសវនាការរបស់អ្នកក្នុងថ្ងៃទី 30 ដែលជា ថ្ងៃផុត កំណត់ ។

## ការបាត់បង់សិទ្ធិស្នើសុំឱ្យមានសវនាការ

ចំណាំ : ដោយសារការបកស្រាយនៃច្បាប់រដ្ឋដែលធ្វើដោយតុលាការឧទ្ធរណ៍មណ្ឌលទី 8 ប្រសិនបើកូនរបស់អ្នក ប្តូរមណ្ឌលសិក្សាស្រុក ហើយអ្នកមិនបានស្នើសុំឱ្យមានសវនាការ នៅមុនពេលដែលកូនរបស់អ្នកបានចុះឈ្មោះចូលរៀននៅ មណ្ឌលសិក្សាស្រុកថ្មី អ្នកអាចបាត់បង់សិទ្ធិ ស្នើសុំឱ្យមានសវនាការ អំពីបញ្ហានានា ពាក់ព័ន្ធនឹងការអប់រំពិសេស ដែលកើតមាននៅក្នុងមណ្ឌលសិក្សា ស្រុក ចាស់របស់កូនអ្នក ។ អ្នកពិតជានៅតែមានសិទ្ធិស្នើសុំឱ្យមានសវនាការ អំពីបញ្ហា ពាក់ព័ន្ធនឹងការ អប់រំពិសេស ដែលអាចកើតមាននៅក្នុងមណ្ឌលសិក្សាថ្មី ដែលកូនរបស់អ្នក កំពុងរៀនជាមួយ ។

## ទម្រង់ការសំរាប់ផ្តួចផ្តើមធ្វើសវានាការតាមទម្រង់ច្បាប់

ក្រោយធ្វើសំណើសុំធ្វើសវនាការ មណ្ឌលសិក្សាស្រុក ត្រូវតែផ្តល់ឱ្យ អ្នកនូវ សំណៅថតចម្លង នៃការជូនដំណឹងអំពីទម្រង់ការការពារ និងសំណៅថត ចម្លង អំពីសិទ្ធិរបស់អ្នកនៅឯសវនាការ ។ ប្រសិនបើរូបអ្នក ឬមណ្ឌលសិក្សាស្រុក ស្នើសុំឱ្យមាន សវនាការ ភាគីម្ខាងទៀត ត្រូវតែបានទទួលនូវ សំណៅថតចម្លងចំពោះការស្នើសុំនេះ ហើយពាក្យសុំធ្វើ សវនាការ ត្រូវតែដាក់ជូនទៅកាន់ក្រសួងអប់រំ ។ នៅ ពេលដែលក្រសួងបាន ទទួលពាក្យសុំហើយ ក្រសួងត្រូវតែ ផ្តល់ឱ្យអ្នកមួយច្បាប់នូវការជូនដំណឹងអំពី ទម្រង់ការការពារមួយច្បាប់យកមកអាន ។ រាល់ សំណើសុំជាលាយលក្ខណ៍ អក្សរ ត្រូវតែរួមបញ្ចូលនូវ :

1. ឈ្មោះរបស់កូនអ្នក
2. អាសយដ្ឋានរបស់កូនអ្នក
3. ឈ្មោះសាលារៀនរបស់កូនអ្នក
4. ការពណ៌នាអំពីបញ្ហា ដោយរួមទាំង ទស្សនៈរបស់អ្នក ចំពោះតថភាព និង
5. សំណើចំពោះដំណោះស្រាយ លើបញ្ហាដែលកើតឡើង ដល់ចំណុចមួយដែល ដឹងបាន និងមានចំពោះអ្នក នាពេលនោះ ។

MDE ជាអ្នករក្សាទុកនូវបញ្ជីឈ្មោះរបស់មន្ត្រីសវនាការ ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ។ ឆ្លងតាមការបានទទួល នូវសំណើសុំឱ្យមានសវនាការ ជាលាយលក្ខណ៍អក្សរ MDE នឹងចាត់តាំងមន្ត្រីសវនាការ ចេញពីបញ្ជីឈ្មោះនោះ ឱ្យរៀបចំធ្វើសវនាការ ។ ខាងក្រោមគឺជាសិទ្ធិមួយចំនួនរបស់អ្នក នៅសវនាការ ។ នេះមិនមែនជា បញ្ជីពេញលេញដែលរៀបរាប់អំពីសិទ្ធិរបស់អ្នក ឡើយ ។

ទាំងរូបអ្នក និងមណ្ឌលសិក្សាស្រុក មានសិទ្ធិ ដើម្បី :

1. សុំឱ្យមានមនុស្សទៅតាម និងទទួលដំបូន្មាន ពីក្រុមប្រឹក្សា និងបុគ្គល ណាមួយដែលមានចំណេះដឹងពិសេស ឬបានទទួលការ បណ្តុះបណ្តាល ដែលពាក់ព័ន្ធនឹងបញ្ហារបស់កុមារពិការ

2. បង្ហាញភស្តុតាង និងការពារលើភស្តុតាង ធ្វើការផ្ទៀងផ្ទាត់ និង ការជំរុញឱ្យមានសាក្សីចូលរួម

3. ហាមឃាត់លើការលើកយកភស្តុតាងណាមួយនៅឯសវនាការ ដែលនៅ មិនទាន់បានលាតត្រដាង យ៉ាងហោចណាស់ចំនួន 5ថ្ងៃ នៃថ្ងៃធ្វើការ នៅមុនពេលធ្វើសវនាការ ដោយរួមទាំង ទិន្នន័យការវាយ តម្លៃ និង អនុសាសន៍ ដោយសំអាងលើទិន្នន័យនោះ និង

4. ទទួលបាននូវសំណៅថតចម្លងមួយច្បាប់ដោយមិនបាច់បង់ប្រាក់ អំពី កំណត់ ត្រាលើក្រដាស ឬកំណត់ត្រាអេឡិចត្រូនិច ដែលកត់ត្រាអំពី ការ រកឃើញ តថភាព និងការសម្រេចរបស់សវនាការ ។

ក្នុងនាមជាមាតាបិតា អ្នក មានសិទ្ធិជាពិសេស ដើម្បី :

1. យកកូន ដែលជាអ្នកប្រឈមនឹងសេចរឿងសវនាការ ទៅបង្ហាញខ្លួន នៅឯសវនាការ

2. បើកសវនាការ ចំពោះសាធារណៈជន និង

3. បានទទួលនូវកំណត់ត្រា ឬការសរសេរលើក្រដាសនៃសវនាការ និងការរក ឃើញតថភាពដោយមន្ត្រីសវនាការ ការសរុបនៃច្បាប់ ព្រមទាំងការ សម្រេចចិត្តដែលបានធ្វើឡើង ដែលត្រូវផ្តល់ឱ្យអ្នក ដោយមិនបាច់ចំណាយ អ្វីឡើយ ។

## ការឆ្លើយតបចំពោះសំណើសុំឱ្យមានសវនាការ

ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងស្នើសុំឱ្យមានសវនាការ ហើយកាលពីមុនមកអ្នក មិនបានទទួល ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនពីមណ្ឌលសិក្សាស្រុក អំពី ប្រធានបទចំពោះសវនាការ នៃការស្នើសុំឱ្យមានសវនាការ មណ្ឌលសិក្សាស្រុកត្រូវតែផ្ញើឱ្យអ្នកនូវការពន្យល់ជាលាយលក្ខណ៍អក្សរ អំពីមូលហេតុដែល មណ្ឌលសិក្សាស្រុកបដិសេធមិនធ្វើសកម្មភាព ដែលបានស្នើឡើង នៅក្នុងការ ស្នើសុំធ្វើសវនាការ ក្នុងរវាង 10ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំឱ្យមាន សវនាការ ។ ការពន្យល់នោះ ត្រូវតែរួមបញ្ចូលនូវ ការពណ៌នាអំពីជម្រើសផ្សេង ទៀត ដែលបានស្នើដោយក្រុម IEP  មូលហេតុចំពោះការបដិសេធ លើជម្រើស ទាំងនោះ ការរៀបរាប់អំពីទម្រង់ ការវាយតម្លៃនីមួយៗ ការប៉ាន់ប្រមាណ កំ ណត់ត្រា ឬរបាយការណ៍ ដែលមណ្ឌល សិក្សាស្រុក បានយកមកប្រើជាមូលដ្ឋាន សំរាប់សកម្មភាពដែលបានស្នើសុំ ឬដែលបាន បដិសេធ និងការរៀបរាប់អំពីកត្តា នានា ដែលពាក់ព័ន្ធនឹងសម្រេចចិត្តសុំស្នើ ឬសុំបដិសេធរបស់មណ្ឌលសិក្សាស្រុក ។

មណ្ឌលសិក្សាស្រុកអាចអះអាងថា សំណើសុំឱ្យមានសវនាការ មិនត្រូវតាម ភាពតម្រូវ របស់ច្បាប់រដ្ឋ ។ សំណើសុំឱ្យមានសវនាការ មិនត្រូវបាន គេចាត់ ទុកថា មានភាពគ្រប់គ្រាន់ទេ ប្រសិនបើភាគីដែលបានទទួលការស្នើសុំ ផ្តល់ ដំណឹងដល់មន្ត្រីសវនាការ ក្នុងរវាង 15ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំ ដែលខ្លួនជឿថា ពាក្យសុំនោះមិនបំពេញតាមភាពតម្រូវរបស់ឧបញ្ញត្តិឡើយ ។ មន្ត្រីសវនាការ ត្រូវកំណត់ថា តើពាក្យសុំឱ្យមានសវនាការបំពេញតាមភាពតម្រូវ របស់ឧបញ្ញត្តិ ក្នុងរវាង 5ថ្ងៃ ក្រោយពីការបាន ទទួលពាក្យសុំ ហើយត្រូវផ្តល់ ដំណឹងទៅឱ្យភាគីទាំងពីរបានដឹង ។។

ឆ្លងតាមការបានទទួលពាក្យស្នើសុំឱ្យមានសវនាការរបស់អ្នក មណ្ឌលសិក្សាស្រុក ក៏ត្រូវតែផ្ញើឱ្យអ្នកផងដែរនូវ ការឆ្លើយតបជាលាយលក្ខណ៍អក្សរ ដែលនិយាយ អំពីបញ្ហា ដែលអ្នកបានលើកឡើង នៅក្នុងពាក្យសុំឱ្យមានសវនាការ ក្នុងរវាង 10ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំរបស់អ្នក។

## ការលាតត្រដាងនូវភស្តុតាងបន្ថែម នៅមុនពេលធ្វើសវនាការ

ការប្រជុំនៅមុនពេលធ្វើសវនាការ ត្រូវតែធ្វើឡើង ក្នុងរវាង 5ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលស្នងការបានចាត់តាំងមន្ត្រីសវនាការ ។ ការប្រជុំនេះអាចជួប ជាមួយបុគ្គលផ្ទាល់ នៅកន្លែងមួយក្នុងតំបន់ ឬ តាមរយៈទូរសព្ទ។ យ៉ាងហោចណាស់ 5ថ្ងៃ នៃថ្ងៃធ្វើការ នៅមុនពេល សវនាការ អ្នក និងមណ្ឌលសិក្សាស្រុក ត្រូវតែបង្ហាញគ្នាទៅវិញទៅមក លើគ្រប់ការវាយតម្លៃរបស់កូនអ្នក ដែលបានបញ្ចប់ ដោយគិតមកដល់ ពេលនោះ និងអនុសាសន៍ ដោយសំអាងលើ ការវាយតម្លៃទាំងនោះ ដែលមានបំណងយកទៅប្រើ នៅក្នុងសវនាការ ។ មន្ត្រីសវនាការ អាច បដិសេធមិនអនុញ្ញាតឱ្យអ្នក បង្ហាញនូវការវាយតម្លៃ ឬ អនុសាសន៍ ណា មួយ ដែលមិនបានលាតត្រដាង នៅឯសវនាការ ដោយ គ្មាន ការយល់ ព្រមរបស់ភាគីផ្សេងទៀត។

## ការសម្រេចចិត្តរបស់សវនាការ

ការសម្រេចចចិត្តរបស់សវនាការ ត្រូវតែសរសេរចេញជារូបរាងឡើង ហើយត្រូវ ផ្តល់ឱ្យភាគីនីមួយៗ ក្នុងរវាង 45ថ្ងៃ ដោយគិតតាមប្រតិទិន ឬក្នុងកំឡុងដែល ត្រូវពន្យារដំ សមរម្យមួយ ក្រោយពីផុតកំណត់រយៈពេល 30ថ្ងៃ នៃការរក ដំណោះស្រាយ ក្រោយពីបណ្តឹងឱ្យមានសវនាការ ត្រូវបានបញ្ជូនមកដល់ទី ភ្នាក់ងាររបស់រដ្ឋ ។ មន្ត្រីសវនាការ អាចពន្យារពេលលើសពី 45ថ្ងៃ ប្រសិនបើមានការស្នើពីភាគីណាមួយ ដែលមានមូលហេតុល្អបង្ហាញនៅ ក្នុងកំណត់ត្រា។ មន្ត្រីសវនាការ ត្រូវរៀបចំឱ្យមានការ ជជែកតទល់គ្នាមួយ នៅក្នុងសវនាការ នៅក្នុងពេល និងទីកន្លែងដែលងាយស្រួល ចំពោះអ្នក និងកូនរបស់អ្នក។ ការសម្រេចរបស់មន្ត្រីសវនាការ ថាតើកូនរបស់ត្រូវបានទទួល FAPE ឬទេនោះ ត្រូវតែផ្អែកលើភស្តុតាង និងការជជែកតទល់ផ្ទាល់មាត់ ដែលពាក់ព័ន្ធនឹង FAPE ដោយផ្ទាល់។ ការសម្រេចរបស់សវនាការ គឺជារឿងចុងក្រោយ ប្រសិនបើអ្នក ឬមណ្ឌលសិក្សា ស្រុក មិនធ្វើបណ្តឹងរដ្ឋប្បវេណីទេនោះ ។ មន្ត្រីសវនាការ មិនមានសមត្ថកិច្ចក្នុងការកែប្រែ ការសម្រេច ចិត្តទេ លើកលែងតែមានករណីសរសេរខុស និង ការគិតលេខខុសតែប៉ុណ្ណោះ ។

## សំណើសុំដាច់ដោយឡែក ឱ្យមានសវនាការ

អ្នកមានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងដាច់ដោយឡែកមួយ ឱ្យមានសវនាការ លើបញ្ហាដាច់ដោយលែកពី បណ្តឹងសុំឱ្យមានសវនាការ ដែលបានដាក់រួច ហើយ នោះ ។

## កម្រងទិន្នន័យបណ្តឹង និងសវនាការ

ការសម្រេចជាចុងក្រោយ លើបណ្តឹងការអប់រំពិសេស និងដំណើរការសវនាការ មានជូនសំរាប់សាធារណៈជន នៅក្នុងគេហទំព័ររបស់ MDE។ MDE ធ្វើការរក្សាទុក កម្រងទិន្នន័យសាធារណៈ ដែល គេហៅថា ឧបករណ៍ស្វែងរក ពាក្យបណ្តឹង សវនាការ និងលិខិត ។ សេចក្តី សម្រេចដែលមាននៅក្នុងកម្រងទិន្នន័យ ត្រូវបាន សរសេរជារបៀបតែងឡើង ហើយរាល់ព័ត៌មានបង្ហាញពីអត្តសញ្ញាណកម្មបុគ្គល ត្រូវបានដកចេញទាំងអស់ ។ កម្រងទិន្នន័យនេះ ក៏មាននៅឯគេហទំព័ររបស់ ផ្នែក អនុវត្តច្បាប់ និងផ្តល់ជំនួយ លើការអប់រំពិសេស ដែលនៅក្នុងគេហទំព័ររបស់ MDE តាមរយៈអាសយដ្ឋាន :
http://w20.education.state.mn.us/WebsiteContent/ComplianceSearch.jsp ។

## បណ្តឹងរដ្ឋប្បវេណី

ពេលអ្នក ឬមណ្ឌលសិក្សាស្រុក មិនយល់ព្រមជាមួយនឹងការរកឃើញ ឬការ សម្រេចចិត្ត ដែលធ្វើឡើងដោយមន្ត្រីសវនាការ ភាគីណាមួយ អាច ធ្វើការប្តឹង តុលាការបាន ។ បណ្តឹងនេះ អាចធ្វើនៅតុលាសហព័ន្ធ ប្រចាំ តំបន់ ឬតុលាការ ឧទ្ធរណ៍របស់រដ្ឋ។ តុលាការនីមួយៗ មាន បទដ្ឋានផ្សេង គ្នា នៃការពិនិត្យ ឡើងវិញចំពោះសាច់រឿង ។ ការប្តឹងឧទ្ធរណ៍ ចំពោះ តុលាការឧទ្ធរណ៍របស់រដ្ឋ ត្រូវតែធ្វើឡើងក្នុងរវាង 60ថ្ងៃ ដោយគិតតាមប្រតិទិន ក្រោយពេល អ្នកបានទទួលសេចក្តីសម្រេចចិត្ត។ ការប្តឹងឧទ្ធរណ៍ចំពោះ តុលាការសហព័ន្ធ ប្រចាំតំបន់ ត្រូវតែធ្វើក្នុងរវាង 90ថ្ងៃ ក្រោយពេល ទទួលការធ្វើ សេចក្តីសម្រេចចិត្ត ។

## ការដាក់ឱ្យកូនអ្នកចូលរៀន ក្នុងពេលធ្វើសវនាការ ឬបណ្តឹងរដ្ឋប្បវេណី

ក្នុងរយៈពេលសវនាការ ឬដំណើរការបណ្តឹងរដ្ឋប្បវេណី កូនរបស់អ្នក នឹងត្រូវ បន្តស្ថិតនៅបន្តការរៀនសូត្រដែលគេត្រូវរៀនពីមុនមក លើកលែងតែ សាលា និងអ្នកមិនយល់ព្រម ហើយកូនរបស់អ្នក នឹងមិនត្រូវបានទទួលការបដិសេធ ក្នុងការចូលរៀនពីដំបូងឡើយ ។ ចំណុចនេះ ត្រូវបានគេដឹងជាទូទៅថា "ច្បាប់នៅមួយ កន្លែង" ។

ការលើកលែងចំនួនពីរយ៉ាង ចំពោះ "ច្បាប់នៅមួយកន្លែង" គឺ :

1. សិស្សអាចត្រូវឱ្យចេញពីកន្លែងសិក្សារបស់ខ្លួន មិនលើសពី 45ថ្ងៃ នៃថ្ងៃសិក្សា អំពីការប្តូរទៅកាន់កន្លែងបណ្តោះអាសន្ន ផ្នែកសិក្សា សម្រាប់ការ រំលោភខាងអាវុធ ថ្នាំញៀន ឬការធ្វើឱ្យមានរបួសស្នាមលើ រាងកាយដ៏ធ្ងន់ធ្ងរ និង

2. ការសម្រេចចិត្តរបស់មន្ត្រីសវនាការដែលយល់ព្រមជាមួយនឹងរូបអ្នក ដែលថា ការប្តូរកន្លែងសិក្សាគឺជារឿងសមរម្យ គឺជាការដាក់ការ សិក្សាឱ្យនៅ "មួយកន្លែង" ក្នុងពេលកំពុងធ្វើឧទ្ធរណ៍។

## សវនាការរួសរាន់

អ្នក (មាតាបិតា) ឬមណ្ឌលសិក្សាស្រុកអាចស្នើសុំឱ្យមានសវនាការរួសរាន់បាន តាមស្ថានភាពដូចខាងក្រោម :

1. ពេលណាអ្នក មិនយល់ស្រប ជាមួយនឹង *សំណើ* របស់មណ្ឌលសិក្សាស្រុក ដើម្បីផ្ដួចផ្ដើម ឬផ្លាស់ប្ដូរនូវអត្តសញ្ញាណកម្ម ការវាយតម្លៃ ឬការដាក់ ឱ្យកូនរបស់អ្នករៀនក្នុងថ្នាក់ណាមួយ ឬមិនយល់ស្របជាមួយ នឹងការផ្ដល់ FAPE របស់មណ្ឌលសិក្សាស្រុក ដល់កូនអ្នក

2. ពេលអ្នកមិនយល់ស្រប ចំពោះ *ការបដិសេធ* របស់មណ្ឌលសិក្សាស្រុក ដើម្បីធ្វើការផ្ដួចផ្ដើម ឬ ផ្លាស់ប្ដូរអត្តសញ្ញាណកម្ម ការវាយតម្លៃ ឬការដាក់ ឱ្យកូនអ្នក ចូលរៀននៅក្នុងថ្នាក់ណាមួយ ឬ ការផ្ដល់ FAPE របស់ មណ្ឌលសិក្សាស្រុក ដល់កូនអ្នក

3. ពេលដែលអ្នកមិនយល់ស្របចំពោះការកំណត់ពីមូលហេតុចំពោះការ ប្រព្រឹត្តិរបស់កូនអ្នក និង

4. ពេលដែលមណ្ឌលសិក្សាស្រុក ជឿជាក់ថា ការរក្សាទុកនូវការដាក់ឱ្យកូន អ្នកចូលរៀនក្នុងថ្នាក់ណាមួយ គឺជារឿងដែលសំខាន់ដែលអាចបង្ករបួស ស្នាមដល់កូនអ្នក ឬដល់សិស្សដទៃបាន។

អ្នក ឬមណ្ឌលសិក្សាស្រុក អាចដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរ ស្នើសុំឱ្យ មានសវនាការរួសរាន់មួយ តាមការរៀបរាប់ជូនពីខាងលើស្រាប់។

## ទម្រង់ពេលវេលាសំរាប់សវនាការរួសរាន

សវនាការរួសរាន់ ត្រូវតែរៀបចំធ្វើឡើងក្នុងរវាង 20ថ្ងៃ នៃថ្ងៃសិក្សា ដោយគិត ចាប់ពីពេលដែលភាគីណាមួយបានដាក់ពាក្យបណ្ដឹង ។ មន្ត្រីសវនាការ ត្រូវ បញ្ចេញសេចក្ដីសម្រេចចិត្តក្នុងរវាង 10ថ្ងៃនៃថ្ងៃសិក្សា បន្ទាប់ពីសវនាការ ត្រូវបានបញ្ចប់រួចរាល់ ។ ការប្រជុំរកដំណោះ ស្រាយមួយ ត្រូវតែកើត ឡើងក្នុងរវាង 7ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានទទួលនូវពាក្យ ស្នើសុំឱ្យមានសវនាការ ប្រសិនបើ អ្នក និងមណ្ឌលសិក្សាស្រុក យល់ព្រមនឹងគ្នា ជាលាយលក្ខណ៍អក្សរ ថាត្រូវបោះបង់ចោលការប្រជុំ ឬមិនព្រមប្រើការដោះស្រាយវិវាទ តាមរបៀប ការសម្រុះសម្រួលដោយមានអាជ្ញាកណ្ដាល។ សវនាការ រួសរាន់ អាចត្រូវដំណើរការ ប្រសិនបើវិវាទនោះមិនត្រូវបាន ដោះស្រាយ ប្រកបដោយការពេញចិត្តនឹងលទ្ធ ផលដល់ភាគីទាំងពីរទេនោះ ក្នុងរវាង 15ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានទទួលពាក្យសុំ។

## ការបដិសេធចោលនូវពាក្យបណ្ដឹង

ប្រសិនបើមណ្ឌលសិក្សាស្រុក មិនអាចទាញអ្នកឱ្យចូលរួម បាននៅ ក្នុងការប្រជុំ រកដំណោះស្រាយ ឬការសម្រុះសម្រួលទេ ក្រោយពីខំ ប្រឹង ប្រែងយ៉ាងសម ហេតុផលរួចមក ហើយមណ្ឌលសិក្សាស្រុក នៅតែ មិនចង់បោះបង់ការ ប្រជុំនេះ ជាលាយលក្ខណ៍អក្សរ មណ្ឌលសិក្សាស្រុក អាចស្នើសុំដល់មន្ត្រី សវនាការបោះ បង់ចោលសំណើសុំរបស់អ្នកលើបណ្ដឹងសុំធ្វើ សវនាការតាមទម្រង់ច្បាប់ នៅថ្ងៃទី 30ដែល ជាថ្ងៃផុតកំណត់ ។

## ការដាក់កូនអ្នកឱ្យរៀននៅក្នុងថ្នាក់ណាមួយ ដោយមន្ត្រីសវនាការ

មន្ត្រីសវនាការ អាចសម្រេចឱ្យកូនអ្នកប្ដូរមករៀន នៅកន្លែងរៀបចំ ផ្នែក បណ្ដោះ អាសន្ន រហូតដល់ 45ថ្ងៃ នៃថ្ងៃសិក្សា បើមន្ត្រី សវនាការ រកឃើញថា កូនរបស់ អ្នក អាចស្ថិតក្នុងភាពគ្រោះថ្នាក់ ក្នុងការបង្ក របួសស្នាមលើរាង កាយខ្លួនឯង ឬអ្នកដទៃ បើកូនរបស់អ្នក ត្រូវបន្តស្ថិត នៅក្នុងថ្នាក់រៀនសព្វថ្ងៃ។

## សិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះការសម្រេចរបស់សវនាការ

អ្នក ឬមណ្ឌលសិក្សាស្រុក អាចប្ដឹងឧទ្ធរណ៍ចំពោះការសម្រេចរបស់មន្ត្រីសវនាការ ពីសវនាការរួសរាន់បាន ។

## ការដាក់ឱ្យក្មេងរៀននៅកន្លែងអប់រំបណ្តោះអាសន្ន

មណ្ឌលសិក្សាស្រុក អាចប្តូរកន្លែងឱ្យកូនអ្នករៀន រហូតដល់ 45ថ្ងៃ ប្រសិន បើកូនរបស់អ្នក :

1. កាន់ ឬមានអាវុធដែលមានគ្រោះថ្នាក់ជាប់ខ្លួននៅក្នុងថ្នាក់រៀន ក្នុង បរិវេណសាលារៀន ឬនៅតាមកន្លែងពិធីផ្សេងៗរបស់សាលា ក្រោម យុត្តាធិការ របស់មណ្ឌលសិក្សាស្រុក ឬ MDE ដូចមានចែងក្នុងច្បាប់ របស់សហព័ន្ធ

2. ដឹងថា កូនរបស់អ្នក យក ឬប្រើគ្រឿងញៀនខុសច្បាប់ ឬលក់ ឬសុំលុយ កាសពីសិស្សដទៃ តាមការលក់សារធាតុដែល មានការ ហាមឃាត់ នៅសាលារៀន នៅក្នុងបរិវេណសាលារៀន ឬនៅ តាមកន្លែងពិធីផ្សេងៗ របស់សាលា ក្រោមយុត្តាធិការ របស់ មណ្ឌលសិក្សាស្រុក ឬ MDE ។ ចំណុចនេះមិនរាប់បញ្ចូលនូវគ្រឿងស្រវឹង ឬថ្នាំជក់ទេ ឬ

3. ធ្វើឱ្យមានរបួសស្នាមលើរាងកាយសិស្សដទៃយ៉ាងធ្ងន់ធ្ងរ នៅ សាលារៀន នៅក្នុងបរិវេណសាលារៀន ឬនៅតាមកន្លែង ពិធីផ្សេងៗរបស់សាលា ក្រោមយុត្តាធិការ របស់មណ្ឌល សិក្សាស្រុក ឬ MDE ដូចមានចែងនៅ ក្នុងច្បាប់របស់សហព័ន្ធ។

នៅថ្ងៃដែល មណ្ឌលសិក្សាស្រុក សម្រេចចិត្ត ដកកូនអ្នកចេញពីសាលា ហើយការ ដកកូនអ្នកចេញ គឺជាកាប្តូរ កន្លែងសិក្សារបស់ក្មេងពិការ ដោយសារតែការ ប្រព្រឹត្តិរំលោភលើ វិន័យរបស់សិស្ស មណ្ឌលសិក្សាស្រុក ត្រូវតែផ្តល់ដំណឹងដល់ អ្នក អំពីការសម្រេចចិត្តនេះ ព្រមទាំងផ្តល់ដល់អ្នក នូវដំណឹងអំពី ទម្រង់ការ ការពារ។

ក្រុម IEP/IIIP កំណត់ពី ការរៀបចំការអប់រំអន្តរកាលបណ្តោះអាសន្នផ្សេងៗ និងសេវាអប់រំពិសេស ដែលសមស្រប សម្រាប់កូនអ្នក ។ បើទោះបីនេះ គឺជាការប្តូរជាបណ្តោះ អាសន្នក៏ដោយ វាត្រូវតែ ជួយដល់កូនអ្នកឱ្យបាន :

1. បន្តចូលរួមក្នុងកម្មវិធីការអប់រំទូទៅ និងដំណើរការ ដើម្បីឈាន ទៅរក គោលបំណង ដែលបានសរសេរទុកនៅក្នុង IEP របស់កូនអ្នក បើទោះបីជា វានៅក្នុងការរៀបចំផ្សេងក៏ដោយ និង

2. រួមបញ្ចូលនូវសេវានានា និងការកែតម្រូវ ដែលរចនាឡើង ដើម្បីរារាំង កុំឱ្យកុមារ មានអាកប្បកិរិយា ដូចកាលពីលើកមុន ។

ប្រសិនបើកូនអ្នក ត្រូវបានដាក់ឱ្យរៀនក្នុងការរៀបចំអប់រំជាបណ្តោះ អាសន្ន អន្តរកាល ការប្រជុំ IEP/IIIP ត្រូវតែធ្វើឡើង ក្នុងរង្វង់ 10ថ្ងៃ តាមកាលវិភាគ សាលានៃការធ្វើសេចក្តីសម្រេចចិត្ត។ ក្នុងការប្រជុំនេះ ក្រុមត្រូវតែ ពិភាក្សាគ្នាលើអាកប្បកិរិយា និងទំនាក់ទំនងរបស់ វាមក លើពិការភាព របស់កូនអ្នក ។ ក្រុមត្រូវតែពិនិត្យមើលឡើងវិញនូវ ព័ត៌ មានលើការ វាយតម្លៃ ពាក់ព័ន្ធនឹង អាកប្បកិរិយា ហើយកំណត់រក ភាពសម រម្យនៃ IEP/IIIP របស់កូនអ្នក និងកំណត់ផែនការអាកប្បកិរិយា ។ បន្ទាប់មក ក្រុម នឹងកំណត់ថាតើ ការប្រព្រឹត្តិរបស់កូនអ្នក គឺបណ្តាលមកពី ឬមានទំនាក់ ទំនងដោយផ្ទាល់ ចំពោះ ពិការភាពរបស់គេ ឬថាការប្រព្រឹត្តិរបស់កូនអ្នក គឺជាលទ្ធផលដោយផ្ទាល់ ដែលបណ្តាលមកពីបរាជ័យក្នុងការអនុវត្ត IEP របស់មណ្ឌលសិក្សាស្រុក ។

## តម្លៃមេធាវី សំរាប់ពេលសវនាការ

អ្នកអាចមានសិទ្ធិដើម្បីទទួលថ្លៃមេធាវីមកវិញ បើអ្នកឈ្នះក្តី ក្នុងសវនាការ។ ចៅ ក្រមអាចសម្រេចផ្តល់ប្រាក់ថ្លៃ មេធាវី ដោយយោងលើ អត្រាឈ្នះក្តីនៅក្នុង សហគមន៍របស់អ្នក។ ចៅក្រមអាចកាត់បន្ថយ ការសម្រេចផ្តល់ថ្លៃ មេធាវី បើគេរក ឃើញថា អ្នកពន្យារពេលក្នុងការដោះស្រាយ ឬសេចក្តី សម្រេចចិត្ត លើ បណ្តឹងនេះដោយគ្មានហេតុផលច្បាស់លាស់ ។ បើមណ្ឌលសិក្សាស្រុកជាអ្នកឈ្នះក្តី ហើយតុលាការ យល់ព្រមថា សំណើធ្វើសវនាការរបស់អ្នក មិនមានគោលបំណង សមរម្យទេ គេអាច តម្រូវឱ្យអ្នកបង់ថ្លៃមេធាវីរបស់មណ្ឌលសិក្សាស្រុក ផងដែរ ។

## ការមិនរាប់បញ្ចូល និងការបណ្តេញចោល ចំពោះសិស្សពិការ

មុនពេលដែលកូនដែលមានពិការភាពរបស់អ្នក ត្រូវបានគេបណ្តេញចេញពីសាលា គឺត្រូវតែ មានការប្រជុំដដែលដេញដោយគ្នាមួយ កំណត់ពីមូលហេតុនៃការ ប្រព្រឹត្តិរបស់កុមារ។ ប្រសិនបើការ ប្រព្រឹត្តិមិនល្អរបស់ កូនអ្នក មានពាក់ព័ន្ធនឹងពិការភាពរបស់គេ សាលាមិនអាច បណ្តេញកូនអ្នក ចេញពីសាលាបានឡើយ ។ ពេលដែលកូនដែលមាន

ពិការភាព ត្រូវបានគេដកចេញពីបញ្ជី ឬត្រូវបានគេបណ្តេញចេញពីសាលា ដែលស្ថិតនៅ ក្រោម Pupil Fair Dismissal Act (ច្បាប់ការបណ្តេញ ក្មេងចេញប្រកប ដោយយុត្តិធម៌) ដែលជាឧបញ្ញត្តិរបស់រដ្ឋមីណេសូតា ត្រង់ផ្នែកទី 121A.41-56 សម្រាប់ការ ប្រព្រឹត្តិមិនល្អ ដែលនៅត្រង់ចំណុចនេះ ច្បាប់ មិនបាននិយាយ សំដៅលើពិការភាពរបស់កុមារ មណ្ឌលសិក្សាស្រុក គួរតែបន្ត ផ្តល់សេវាការ អប់រំពិសេស និងសេវាដទៃទៀតដែលពាក់ព័ន្ធ ដល់សិស្សរូបនោះ នៅក្នុងកំឡុង ពេលនៃការ ព្យួរមិនឱ្យចូលសាលា ប្រសិនបើច្បាប់តម្រូវឱ្យធ្វើ ។

## ការពិន័យដោយការបណ្តេញចេញ

ប្រសិនបើកុមារមានពិការភាព ត្រូវបានគេបណ្តេញចេញពីសាលា គឺត្រូវបាន គេចាត់ទុកថា ជាការប្តូរកន្លែងរៀន ប្រសិនបើ :

1. ការបណ្តេញចេញមានរយៈពេលច្រើនជាង 10ថ្ងៃជាប់ៗគ្នា នៃថ្ងៃសិក្សា
   ឬ

2. កូនរបស់អ្នក ត្រូវបានគេបណ្តេញចេញជាបន្តៗ ដែលការដេញចេញនេះ បង្កើតបានជាទម្រង់មួយ ពីព្រោះថា :

   ក. ការដេញចេញជាបន្តៗ សរុបទៅមានចំនួនច្រើនជាង 10ថ្ងៃ នៃថ្ងៃសិក្សា ក្នុងមួយឆ្នាំ

   ខ. ការប្រព្រឹត្តិរបស់កូនអ្នក គឺមានភាពដូចគ្នាទៅនឹងការប្រព្រឹត្តិរបស់គេ កាលពីពេលមុន ដែលត្រូវដេញចេញពីសាលាដែរ និង

   គ. មានកត្តាផ្សេងទៀត ដូចជា រយៈពេលនៃការបណ្តេញចេញម្តងៗ សរុប ពេលដែលកូនរបស់អ្នកត្រូវគេបណ្តេញចេញ និងគម្លាតគ្នារវាង ការបណ្តេញចេញមួយលើកៗ ។

ការកំណត់ថាតើ ទំរង់នៃការបណ្តេញចេញ ដែលអាចនាំឱ្យមានការប្តូរកន្លែងរៀន របស់សិស្ស ត្រូវធ្វើឡើងដោយមណ្ឌលសិក្សាស្រុក ។ បើការកំណត់នេះត្រូវបានទទួលការប្រឆាំង គេត្រូវ លើកយកវាមកពិនិត្យមើលឡើងវិញនៅក្នុងសវនាការ ឬនៅក្នុងដំណើការ កាត់ក្តីតាមរយៈតុលាការ ។

## កុមារដែលមិនត្រូវបានគេកំណត់ថាត្រូវមានសិទ្ធិទទួលសេវាអប់រំពិសេស និងសេវាដទៃទៀតដែលពាក់ព័ន្ធ

ប្រសិនបើកូនរបស់អ្នក មិនត្រូវបានគេកំណត់ថាមានសិទ្ធិទទួលសេវាអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធទេនោះ ហើយកូនរបស់អ្នកបានប្រព្រឹត្តខុស វិន័យសិស្ស ហើយមណ្ឌលសិក្សាស្រុកបានដឹងនៅមុនពេលដែលកូនអ្នកបាន ប្រព្រឹត្តខុសថា កូនរបស់អ្នកជាកុមារមានពិការភាព ពេលនោះកូនរបស់អ្នក អាចប្រើ ទម្រង់ការការពារ ដែលមានចែងនៅក្នុងឯកសារជូនដំណឹងនេះ ។

មណ្ឌលសិក្សាស្រុក ត្រូវបានគេគិតថា បានដឹងថា កូនរបស់អ្នកជាកុមារមាន ពិការភាព ប្រសិនបើ នៅមុនពេលដែលការប្រព្រឹត្តិខុសដែលត្រូវពិន័យនោះ បានកើតឡើង :

1. អ្នកបានប្រាប់ពីការព្រួយបារម្ភរបស់ខ្លួន ជាលាយលក្ខណ៍អក្សរ ទៅកាន់ អ្នកគ្រប់គ្រង ឬបុគ្គលិករដ្ឋបាល នៅឯមណ្ឌលសិក្សាស្រុក ឬគ្រូរបស់ កូនអ្នក ដោយបញ្ជាក់ថា កូនរបស់អ្នក ត្រូវការនូវសេវាអប់រំពិសេស និងសេវាដទៃទៀត ដែលពាក់ព័ន្ធ

2. អ្នកបានស្នើសុំឱ្យមានការវាយតម្លៃ ពាក់ព័ន្ធនឹងសិទ្ធិទទួលសេវាអប់រំពិ សេស និងសេវាដទៃទៀតដែលពាក់ព័ន្ធ សំរាប់កូនអ្នក ក្រោមផ្នែក ខ នៃ IDEA ឬ

3. គ្រូរបស់កូនអ្នក ឬមន្ត្រីមណ្ឌលសិក្សាស្រុកដទៃទៀត បានបង្ហាញនូវការ បារម្ភជាក់លាក់មួយចំនួន អំពីទម្រង់នៃការប្រព្រឹត្តិដែលស្តែងចេញពី កូនអ្នក ដោយផ្ទាល់ទៅកាន់ នាយកមណ្ឌលសិក្សាស្រុក ទទួលបន្ទុកផ្នែក ការអប់រំពិសេស ឬទៅកាន់អ្នកគ្រប់គ្រងដទៃទៀត នៅក្នុងមណ្ឌលសិក្សាស្រុក ។

## ការលើកលែងចំពោះអ្វីដែលមណ្ឌលសិក្សាស្រុកបានដឹង

មណ្ឌលសិក្សាស្រុក មិនត្រូវបានគេគិតថា បានដឹងនូវរឿងរ៉ាវទេ ប្រសិនបើ :

1. កាលពីពេលមុន អ្នកបានបដិសេធមិនព្រមឱ្យសាលាធ្វើការវាយតម្លៃចំពោះ កូនអ្នក ឬមួយអ្នកធ្លាប់បានបដិសេធមិនទទួលសេវាអប់រំពិសេស ដល់កូន អ្នក ឬ

2. កូនរបស់អ្នក បានទទួលការវាយតម្លៃរួចហើយ ហើយត្រូវបានគេកំណត់ថា មិនមែនជាកុមារមានពិការភាព ក្រោមផ្នែក ខ នៃ IDEA ទេ ។

## លក្ខខណ្ឌដែលត្រូវយកមកប្រើ ប្រសិនបើសាលាមិនបានដឹងរឿងរ៉ាវជា មូលដ្ឋាន

ប្រសិនបើមណ្ឌលសិក្សាស្រុក មិនបានដឹងថា កូនរបស់អ្នកជាកុមារមានពិការភាព នៅមុនពេលដាក់ពិន័យ ចំពោះរូបគេ នោះកូនរបស់អ្នកត្រូវទទួលពិន័យ ដូចអ្វីដែលសាលាត្រូវធ្វើចំពោះសិស្សដទៃដែលមិនពិការ ដែលប្រព្រឹត្តខុស ក្នុង លក្ខណៈដូចគ្នានេះ ។

ប្រសិនបើមានការស្នើសុំឱ្យធ្វើការវាយតម្លៃលើកូនអ្នក ក្នុងកំឡុងពេលជាមួយ នឹងការចាត់វិធានការដាក់ពិន័យដល់កូនអ្នក ការវាយតម្លៃនោះ ត្រូវតែធ្វើឡើង ក្នុងលក្ខណៈបន្ទាន់ ។ នៅមុនពេល ដែលការវាយតម្លៃមិនទាន់ចប់សព្វគ្រប់ កូនរបស់អ្នក ត្រូវរៀននៅក្នុងកន្លែង ដែលមណ្ឌលសិក្សាស្រុកជាអ្នកសម្រេច ដែលអាចរួមទាំងការព្យួរ ឬការបដិសេធ មិនឱ្យទទួលនូវសេវាការអប់រំ ។ នៅរដ្ឋមីណេសូតា សេវាអប់រំពិសេស ដែលទៀងទាត់ ត្រូវបានផ្តល់ជូនដល់សិស្ស នៅក្នុងថ្ងៃទីប្រាំមួយ នៃការព្យួរការចូលរៀននៅក្នុងសាលាធម្មតា ហើយក៏មានការ ផ្តល់ជូននូវសេវាអប់រំតាមវិធីផ្សេងទៀតដែរ ។

## ការបញ្ជូនកុមារ និងចំណាត់ការតាមការអនុវត្តច្បាប់ ព្រមទាំងអាជ្ញាធរយុត្តាធិការ

មណ្ឌលសិក្សាស្រុក អាចរាយការណ៍អំពីបទឧក្រិដ្ឋដែលកុមារមានពិការភាពជា អ្នកប្រព្រឹត្ត ទៅកាន់អាជ្ញាធរដែលសមស្រប និងក្រុមអនុវត្តច្បាប់របស់រដ្ឋ ព្រម ទាំងអាជ្ញាធរតុលាការ ដែលអាចអនុវត្តការទទួលខុសត្រូវរបស់ខ្លួន ក្រោមច្បាប់ ពាក់ព័ន្ធនឹង បទឧក្រិដ្ឋ ដែលប្រព្រឹត្តដោយកុមារមានពិការភាព។

## ការបញ្ជូនបាននូវកំណត់ត្រារបស់សិស្ស

ការបញ្ជូនកំណត់ត្រា ប្រសិនបើមណ្ឌលសិក្សាស្រុករាយការណ៍អំពីបទឧក្រិដ្ឋដែលប្រព្រឹត្តដោយកុមារមានពិការភាព មណ្ឌលសិក្សាស្រុកត្រូវតែធានាថា ខ្លួនបានបញ្ជូននូវសំណៅថតចម្លងអំពី កំណត់ត្រានៃការអប់រំពិសេស និងការពិន័យដល់សិស្សរូបនោះ ទៅកាន់អាជ្ញាធរ សមស្រប ដែលបានទទួលការរាយការណ៍អំពីការប្រព្រឹត្តិបទ ឧក្រិដ្ឋរបស់កុមារ ដើម្បីពិចារណា ។ ទោះជាយ៉ាងណាក៏ដោយ មណ្ឌលសិក្សា ស្រុក អាចបញ្ជូនបាន ត្រឹមតែកំណត់ត្រាអំពីការអប់រំពិសេស និងកំណត់ត្រាការ ពិន័យដល់រូបគេទៅតាមអ្វី ដែល FERPA បានកំណត់ប៉ុណ្ណោះ។

## ការដាក់កូនអ្នកឱ្យរៀននៅសាលារៀនឯកជន

IDEA មិនតម្រូវឱ្យមណ្ឌលសិក្សាស្រុកជាអ្នកចេញថ្លៃលើការអប់រំរបស់ កូនអ្នក ដោយរួមទាំងថ្លៃសេវាអប់រំពិសេស និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ ទៅឱ្យសាលាឯកជន ប្រសិនបើមណ្ឌលសិក្សាស្រុកមានផ្តល់ជូននូវ FAPE ចំពោះ កូន របស់អ្នក ហើយអ្នកសម្រេចដាក់ឱ្យកូនរបស់អ្នករៀននៅឯសាលាឯកជន ។ ទោះជាយ៉ាងណាក៏ដោយ អ្នកប្រហែល ជាអាចបានទទួលមកវិញនូវថ្លៃសាលា ដែលបានចំណាយ សម្រាប់ការដាក់ឱ្យកូនអ្នក រៀននៅសាលាឯកជន ប្រសិនបើអ្នកផ្តល់ដំណឹង ដល់មណ្ឌលសិក្សាស្រុក ពីបំណងរបស់អ្នកក្នុងការបញ្ជូនកូនឱ្យទៅរៀន នៅសាលារៀនឯកជន ដែលរដ្ឋ ត្រូវបង់លើចំណាយ ។ នេះគឺជាការធ្វើឱ្យបាន ទាន់ពេល ហើយប្រសិនបើមន្ត្រី សវនាការរកឃើញថា មណ្ឌលសិក្សាស្រុក មិនមានផ្តល់ជូននូវ FAPE ឱ្យកូន អ្នកបានទាន់ពេល នៅមុនពេលដែលកូន របស់អ្នក ត្រូវចុះឈ្មោះនៅសាលា ឯកជន ហើយបើគេឃើញថា ការឱ្យកូនរៀន នៅសាលាឯកជនគឺជារឿងសម រម្យនោះ ។ អ្នកត្រូវតែផ្តល់ដំណឹងដល់មណ្ឌល សិក្សាស្រុក អំពីបំណងរបស់អ្នក ក្នុងការដាក់ឱ្យកូនអ្នករៀននៅសាលាឯកជន ដែលរដ្ឋជាអ្នកបង់ថ្លៃជូន នៅឯការ ប្រជុំ IEP/IIIP ដែលថ្មីៗបំផុត មុនពេលការ យកកូន អ្នកចេញពីសាលារដ្ឋ ឬដោយការផ្តល់ដំណឹងជាលាយលក្ខណ៍ អក្សរ ដល់មណ្ឌលសិក្សាស្រុក យ៉ាង ហោចណាស់ចំនួន 10ថ្ងៃ នៃថ្ងៃធ្វើ ការនៅមុន ពេលយកកូនអ្នកចេញ ពីសាលារដ្ឋ។

សេចក្តីជូនដំណឹងរបស់អ្នក ត្រូវតែនិយាយពីមូលហេតុដែលអ្នកមិនយល់ព្រម ជាមួយនឹងសំណើ IEP/IIIP របស់មណ្ឌលសិក្សាស្រុក ឬការដាក់ ឱ្យកូនអ្នករៀន ។ ប្រសិនបើ មន្ត្រីសវនាការ ឬតុលាការ រកឃើញថា មណ្ឌលសិក្សាស្រុក ខកខាន មិនបានផ្តល់ជូនកូនអ្នកនូវការអប់រំដែល សមរម្យ ហើយថា ការដាក់ឱ្យកូនអ្នក ចូលរៀននៅសាលាឯកជន មានភាពសមរម្យ អ្នកអាចនឹងបានទទួលសំណង សម្រាប់ចំណាយលើថ្លៃ សម្រាប់កូនអ្នករៀនសូត្រ នៅសាលាឯកជន ។ ការខក ខាន មិនបានប្រាប់មណ្ឌលសិក្សាស្រុក ពីបំណងដាក់ ឱ្យកូនអ្នកចូលរៀននៅសាលា ឯកជន លើការចំណាយរបស់សាធារណៈ ការខកខានមិនបាននាំកូនឱ្យមកទទួល ការវាយតម្លៃ នៅមុនពេលឱ្យកូនអ្នកទៅចូល រៀន នៅសាលាឯកជន ក្រោយ ពេលដែលមណ្ឌលសិក្សាស្រុក បានជូនដំណឹងដល់អ្នក ដោយប្រាប់ពីបំណង របស់ខ្លួន ដើម្បីវាយតម្លៃកូនរបស់អ្នក ឬការពន្យារដទៃ ទៀត ដែលមិនមាន មូលហេតុសមរម្យរបស់អ្នក អាចបណ្តាលឱ្យមានការ កាត់បន្ថយ ឬបដិសេធ មិនបើកប្រាក់ចំណាយលើការឱ្យកូនអ្នក រៀននៅសាលាឯកជន។

មន្ត្រីសវនការ មិនអាចកាត់បន្ថយ ឬបដិសេធ មិនបើកប្រាក់ចំណាយលើការ ដាក់ឱ្យកូនទៅរៀននៅសាលាឯកជន របស់អ្នកបានទេ ប្រសិនបើ : មណ្ឌលសិក្សាស្រុកបាន រារាំងមិនឱ្យអ្នកបានទទួលនូវការជូនដំណឹងនេះ ហើយអ្នកក៏មិនបាន ទទួលការជូនដំណឹង បញ្ជាក់អំពីការទទួលខុសត្រូវរបស់អ្នក ដូចបានរៀបរាប់ពី ខាងលើ ឬប្រសិនបើការ អនុវត្តន៏តាមនូវភាពតម្រូវពីខាងលើ អាចនាំឱ្យមាន គ្រោះថ្នាក់ខាងរាងកាយដល់ កូនរបស់អ្នក ហើយអ្នកខកខានមិនបានផ្តល់ នូវដំណឹងតាមភាពតម្រូវ ដោយសារថាអ្នក មិនចេះសរសេរលិខិតជាភាសា អង់គ្លេស ឬមួយថាបើអនុវត្តតាមភាពតម្រូវ ដូចមានចែងពីខាងលើ អាចនឹង នាំឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរខាងផ្លូវចិត្ត ចំពោះកូនអ្នក។